ក្រសួងអប់រំ យុវជន និងកីឡា



# ក្លឹបថតរូប

២០២៣

# ឯកសារណែនាំសម្រាប់ភ្លឹបថតរូប

ការណែនាំជាក់ស្តែងដើម្បីលើកកម្ពស់ការថតរូប





ឯកសារបោះពុម្ពនេះ ត្រូវបានរៀបចំចងក្រងឡើង ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USE-SDP-2) របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រោមកិច្ចសហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីចងក្រងជាឯកសារនវានុវត្តក្នុងការបង្កើត និងការដឹកនាំក្លឹប។

**រូបភាពក្របសៀវភៅ:** រចនាដោយលោក អឿ សារីន អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

© ក្រសួង អ.យ.ក ២០២៣

# មាតិកា


**បុព្វកថា** ........ iv

**១. សេចក្តីផ្តើម** ........ ១

**២. លទ្ធផលសិក្សា** ........ ២

២.១. វត្ថុបំណង ........ ២

២.២. លទ្ធផល ........ ២

**៣. សម្ភារៈ** ........ ២

**៤. ដំណើរការអនុវត្ត** ........ ២

៤.១. គោលការណ៍រៀបចំ ........ ២

៤.១.១. ការស្ម័គ្រចិត្ត ........ ២

៤.១.២. ទំហំ ........ ៣

៤.១.៣. កម្រិតថ្នាក់គោលដៅ ........ ៣

៤.១.៤. ការវាយតម្លៃចំណាប់អារម្មណ៍សិស្សនិងការតម្រង់ទិស ........ ៣

៤.១.៥. ការបែងចែកនារកិច្ច ........ ៤

៤.១.៦. ការកំណត់ផែនការ ........ ៥

៤.១.៧. ការកំណត់ធនធាន ........ ៥

៤.២. សកម្មភាពស្នើឡើង ........ ៦

៤.២.១ ចំណេះដឹងមូលដ្ឋានគ្រឹះនៃការថតរូប ........ ៧

៤.២.២. ការពិភាក្សា អំពីរូបភាព ........ ១៤

៤.២.៣. ការបង្កើតខ្សែរឿងរូបភាព ........ ២១

៤.២.៤. ទស្សនកិច្ចសិក្សា ........ ២៣

៤.២.៥. ការរៀបចំការតាំងពិព័រណ៍ ........ ២៥

៤.២.៦. ការប្រជុំឆ្លុះបញ្ចាំងសកម្មភាពប្រចាំឆ្នាំ ........ ២៥

**ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស** ........ ២៦

**ឧបសម្ព័ន្ធទី២៖ ការបែងចែកនារកិច្ច** ........ ២៧

**ឧបសម្ព័ន្ធទី៣៖ កំណត់ផែនការ** ........ ២៨

**ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន** ........ ៣០

# មុខកថា

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការអប់រំបានបណ្តុះនូវមូលធនមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការវិជ្ជាជីវៈសម្រាប់សង្គមជាតិ។ ក្នុងបរិការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងឯកសារក្លឹបសិក្សាបន្ថែមសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានមធ្យមសិក្សា។

ឯកសារនេះ នឹងផ្តល់នូវទិដ្ឋភាពថ្មីៗ ដល់សិស្សានុសិស្សទាំងអស់ដែលត្រូវការសិក្សាបន្ថែមក្រៅពីការរៀននៅក្នុងថ្នាក់រៀន។ ការបង្កើតក្លឹបសិក្សា គឺជាការងារស្ម័គ្រចិត្ត ដែលនឹងត្រូវជ្រើសរើសយកទៅអនុវត្តតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានមធ្យមសិក្សា។ ការណ៍នេះ សិស្សានុសិស្ស នឹងទទួលបានឱកាសអភិវឌ្ឍគុណសម្បទាផ្ទាល់ខ្លួនបន្ថែមទៀត តាមរយៈការចូលរួមសកម្មភាពក្លឹបសិក្សា ណាមួយដែលពួកគេចាប់អារម្មណ៍។ ការផ្តល់សេវាអប់រំមានលក្ខណៈសម្បូរបែបនេះ នឹងមានផលជះវិជ្ជមាន ដល់ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់សិស្សានុសិស្ស ឱ្យមានលទ្ធភាពសម្របខ្លួនទៅនឹងការវិវត្តជឿនលឿននៃសង្គមជាតិក្នុងយុគសម័យឌីជីថល។

ការបង្កើតក្លឹបសិក្សា ទាមទារឱ្យមានយន្តការណែនាំច្បាស់លាស់អំពី តួនាទី និងភារកិច្ច សម្រាប់គ្រូដឹកនាំ និងសមាជិកក្លឹប តម្រូវការធនធានគាំទ្រ លំនាំសកម្មភាពត្រូវអនុវត្ត និងប្រធានបទដែលត្រូវសិក្សាក្នុងអំឡុងពេលដំណើរការក្លឹប។ ឯកសារនេះ បានផ្តល់នូវមូលដ្ឋានច្បាស់លាស់ដល់គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ ក្នុងការចាត់ចែង រៀបចំ បង្កើតឱ្យមានក្លឹបសិក្សានៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន ដើម្បីផ្តល់ឱកាសដល់សិស្ស ដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសកម្មភាពក្លឹបណាមួយដោយការស្ម័គ្រចិត្ត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានមធ្យមសិក្សា នឹងប្រើប្រាស់ឯកសារនេះជាមូលដ្ឋានក្នុងការបង្កើតក្លឹបសិក្សា ដោយបត់បែនតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន ប្រកបដោយប្រសិទ្ធភាព សំដៅរួមចំណែកកសាង និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ។

ថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

## ១. សេចក្តីផ្តើម

ការថតរូប មានសារៈសំខាន់ណាស់ក្នុងសង្គមបច្ចុប្បន្នទូទាំងពិភពលោក។ រូបភាពមាននៅគ្រប់ទីកន្លែង ហើយភ្ជាប់មកជាមួយសារផ្សេងៗគ្នា។ រូបភាពទាំងនោះជាវិធីចែករំលែកអារម្មណ៍ និងផ្សព្វផ្សាយព័ត៌មានទូទាំងពិភពលោក។ ការថតរូបឌីជីថល គឺជាការផ្តិតយករូបភាពភ្លាមៗសកម្មភាព និងព្រឹត្តការណ៍ពិសេសផ្សេងៗទាក់ទងនឹងជីវិតយើង។ ឯកសារណែនាំនេះ បង្កើតឡើងដើម្បីរួមបញ្ចូលនូវទម្រង់សិល្បៈថតរូបទៅក្នុងកម្មវិធីសិក្សា។

ក្លឹបថតរូប ត្រូវបានបង្កើតឡើងសម្រាប់ជួយដល់សាលារៀនមធ្យមសិក្សា ដែលនឹងផ្តល់ឱកាសដល់សិស្សក្នុងការរៀនថតរូបភាពផ្សេងៗ។ម្យ៉ាងទៀតការថតរូបមានច្រើនប្រភេទ អាចត្រូវបានចាត់ទុកថាជាទម្រង់មួយនៃសិល្បៈដែលជាមធ្យោបាយសម្រាប់ទំនាក់ទំនង ការបញ្ចេញមតិ ចំណង់ចំណូលចិត្ត ឬអាជីពសម្រាប់ការងារមួយចំនួនផ្សេងទៀត។ ក្លឹបនេះ ជួយសិស្សឱ្យទទួលបានបទពិសោធន៍ក្នុងការប្រើប្រាស់ម៉ាស៊ីនថតរូបឌីជីថល។ សិស្សបានរៀនពីចំណេះដឹងបច្ចេកទេសមូលដ្ឋានពីការប្រើប្រាស់ម៉ាស៊ីនថត និងជួយឱ្យពួកគេអាចប្រើវាបានយ៉ាងស្ទាត់ជំនាញ។ សិស្សរៀនអភិវឌ្ឍជំនាញបែបត្រិះរិះពិចារណានៅពេលមើលរូបភាព។ បន្ទាប់មកសិស្សធ្វើសកម្មភាពសប្បាយៗផ្សេងៗដូចជា ការថតរូបតាមទីប្រជុំជន ដំណើរទស្សនកិច្ចសិក្សា និងការបង្កើតខ្សែរឿងរូបភាព ឬធ្វើរបាយការណ៍រូបភាពជាដើម។ ក្លឹបនេះផ្តល់ឱកាសឱ្យសិស្សចែករំលែកអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈបទពិសោធន៍ក្នុងការថតរូប។ ក្លឹបថតរូប ផ្តល់ឱកាសឱ្យសិស្សចាប់យករូបភាពនានាក្នុងពិភពលោកដូចជា៖ ទេសភាព មិត្តភក្តិ និងសាច់ញាតិ ដែលនៅជុំវិញខ្លួន។ សិស្សត្រូវបានផ្លាស់ប្តូរឥរិយាបទពីរបៀបមើលវត្ថុ និងទីកន្លែងដើម្បីរកប្លង់ថតរូបដ៏ស្រស់ស្អាតទៅតាមទីតាំងផ្សេងៗ។ ម៉ាស៊ីនថតរូបឌីជីថល គឺជាឧបករណ៍ដ៏អស្ចារ្យមួយដើម្បីចាប់យករូបភាពនៃព្រឹត្តការណ៍ណាមួយនៃជីវិត និងអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន។ តាមរយៈការបង្រៀនសិស្សអំពីម៉ាស៊ីនថតរូបឌីជីថល គ្រូនឹងផ្តល់ឱ្យសិស្សនូវគន្លឹះសំខាន់ៗសម្រាប់ការថតរូបពីជីវភាពប្រចាំថ្ងៃ ដោយប្រើប្រាស់ម៉ាស៊ីនថតឌីជីថល ឬទូរសព្ទឆ្លាតវៃ។

រាល់សកម្មភាពទាំងអស់ នឹងធ្វើឱ្យសិស្សកាន់តែមានទំនុកចិត្តក្នុងការប្រើប្រាស់ម៉ាស៊ីនថតរូបឌីជីថល ដោយចាប់យកចំណុចសំខាន់ៗនៃរូបភាព។ ម៉្យាងវិញទៀតការថតរូប នឹងបង្កើនចំណេះដឹងសិស្សនៅក្នុងបរិយាកាសមួយប្រកបដោយភាពស្វាហាប់ និងរស់រវើកដោយយោងទៅតាមបញ្ញត្តិសាលាកុមារមេត្រី។

លើសពីនេះទៅទៀត ក្លឹបថតរូបនេះ គឺជាឱកាសមួយសម្រាប់សិស្សដើម្បីអភិវឌ្ឍគំនិតច្នៃប្រតិដ្ឋ និងជំនាញរចនារបស់ពួកគេបានទៀតផង។ ម៉្យាងវិញទៀតសិស្សនឹងអភិវឌ្ឍជំនាញបច្ចេកទេសប្រើម៉ាស៊ីនថតរូប ការជជែកដេញដោលគ្នា និងបំណិនទំនាក់ទំនងផ្សេងៗ។

ក្លឹបនេះត្រូវបានរៀបចំឡើងក្រៅម៉ោងសិក្សា ដោយមានគ្រូម្នាក់ជាអ្នកសម្របសម្រួល។ សមាជិកទាំងអស់ក្នុងក្លឹបត្រូវបានរៀបចំតាមរយៈការស្ម័គ្រចិត្ត។ វត្ថុបំណងនៃក្លឹបថតរូបនេះ គឺដើម្បីរៀបចំពីសកម្មភាពតាមរចនាសម្ព័ន្ធ ដែលសិស្សបានចូលរួមយ៉ាងសកម្ម ។

★ក្លឹបគឺ៖ ការប្រជុំនៃមនុស្សមួយក្រុមដោយមានគោលដៅរួម ឬមានចំណង់ចំណូលចិត្តដូចគ្នាដើម្បីធ្វើកិច្ចការរួម និងផលប្រយោជន៍រួមមួយ។

# ២. លទ្ធផលសិក្សា

## ២.១. វត្ថុបំណង

ក្លឹបថតរូប បង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម៖

- សិស្សមានឱកាសរៀនជំនាញបច្ចេកទេសថ្មីៗ(ការប្រើប្រាស់ម៉ាស៊ីនថតរូបឌីជីថល) សម្រាប់ការកម្សាន្ត និងដើម្បីអភិវឌ្ឍជំនាញតាមរយៈការពិភាក្សា ឬសកម្មភាពច្នៃប្រតិដ្ឋ
- ជួយសិស្សរៀបចំសកម្មភាពដែលជួយពួកគេអភិវឌ្ឍការច្នៃប្រតិដ្ឋ ចំណេះដឹង បច្ចេកទេស ជំនាញធ្វើបទបង្ហាញ និងការចនា។

## ២.២. លទ្ធផល

ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ យើងត្រូវអនុវត្តដូចខាងក្រោម៖

- ដឹកនាំសិស្សទៅរកបច្ចេកវិទ្យាថ្មីដោយប្រើម៉ាស៊ីនថតរូបឌីជីថល
- បង្កើនឱកាសដល់សិស្សឆ្លុះបញ្ចាំងពីរូបភាពជីវិត ដែលអ្នកថតរូបចង់ផ្តល់សារទៅសាធារណជន
- ធ្វើឱ្យសិស្សអភិវឌ្ឍចំណេះដឹង គំនិតច្នៃប្រតិដ្ឋ ធ្វើបទបង្ហាញ ការរចនា និងជំនាញបច្ចេកទេស
- ធ្វើឱ្យសិស្សមានឱកាសកាន់តែច្រើន ដើម្បីបង្ហាញចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងចែករំលែកបេកគំហើញពីការស្រាវជ្រាវជាមួយអ្នកដទៃផ្សេងទៀត។

# ៣. សម្ភារៈ

សម្ភារៈដែលចាំបាច់សម្រាប់សិស្សធ្វើសកម្មភាពមានដូចខាងក្រោម៖

- ម៉ាស៊ីនថតរូប ថេប្លេត ឬទូរសព្ទឆ្លាតវៃ
- ប៊ិក សៀវភៅសរសេរសម្រាប់កត់ត្រា
- ក្រដាសបិទផ្សាយសម្រាប់បង្ហាញសកម្មភាព
- កុំព្យូទ័រ
- ថវិកាសម្រាប់ដំណើរការក្លឹប (ឧទាហរណ៍ ម៉ាស៊ីនថតរូប ដំណើរកម្សាន្ត ការថតចម្លងឯកសារ...)

# ៤. ដំណើរការអនុវត្ត

## ៤.១. គោលការណ៍រៀបចំ

ការបង្កើតក្លឹបថតរូប ត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗមួយចំនួនដែលបានពន្យល់ដូចខាងក្រោម៖

### ៤.១.១. ការស្ម័គ្រចិត្ត

ការចូលរួមក្នុងក្លឹបថតរូប គឺមិនមែនសម្រាប់សិស្សគ្រប់គ្នានោះទេ ហើយអ្នកសម្របសម្រួលសាលារៀនទាំងអស់ត្រូវយល់ថាមិនមានការបង្ខិតបង្ខំសិស្សឱ្យចូលរួមក្នុងក្លឹបនេះទេ។ ពួកគេអាចមានចំណាប់អារម្មណ៍លើក្លឹបផ្សេងៗទៀតដែរ ហើយទាំងអស់នេះគួរអនុវត្តតាមបញ្ញត្តិនៃសាលាកុមារមេត្រី។ ឧទាហរណ៍ ការរៀបចំក្លឹបថតរូប អាចត្រូវបានធ្វើឡើងនៅពេលតែមួយដែលក្លឹបផ្សេងទៀតកំពុងត្រូវបានបង្កើត ពោលគឺប្រហែលជាមានគ្រូណាម្នាក់កំពុងតែបង្កើតក្លឹបសម្រាប់មុខវិជ្ជាផ្សេងៗទៀតដែរដូចជា ក្លឹបប្រវត្តិសាស្ត្រ ក្លឹបនិពន្ធ...។ សិស្ស

ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសដោយខ្លួនឯងនូវប្រភេទមុខវិជ្ជាដែលពួកគេចង់សិក្សាស៊ីជម្រៅ និងសម្រេចថាតើខ្លួនមានពេលវេលា និងចំណាប់អារម្មណ៍យ៉ាងណាក្នុងការចូលរួមក្លឹបនេះ។

ស្រដៀងគ្នានេះដែរ លោកគ្រូ អ្នកគ្រូ មិនត្រូវបង្ខំ ឬចាត់តាំងឱ្យរៀបចំសម្របសម្រួលក្លឹបនោះទេ។ ការពេញចិត្ត និងការចាប់រម្មណ៍របស់គ្រូចំពោះការថតរូប ជាប្រការចាំបាច់ណាស់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លឹប។ យើងគួរគិតថាសេចក្តីពេញចិត្តនោះពិបាកនឹងធានាថាទទួលបានប្រសិនបើមានការបង្ខំគ្រូឱ្យអនុវត្តសកម្មភាពនោះ។ ព្រមជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួន ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្សដូចជាការចូលរួមប្រជុំក្រៅម៉ោងសិក្សា និងសកម្មភាពទស្សនកិច្ចមូលដ្ឋាន។ សាលារៀនត្រូវពិចារណាលើបែបបទនៃការផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូសម្របសម្រួល ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកាសកម្មភាពផ្សេងៗទៀតដូចជា ការបំប៉នសិស្សរៀនយឺត និងកម្មវិធីគេហកិច្ចជាដើម។

### ៤.១.២. ទំហំ

ក្លឹបថតរូបនេះ មានភាពងាយស្រួលក្នុងការគ្រប់គ្រង ប្រសិនបើអនុវត្តក្នុងសាលារៀនតែមួយ ព្រោះសិស្ស និងគ្រូទាំងអស់ស្ថិតនៅកន្លែងតែមួយ។ ក្នុងករណីខ្លះសាលារៀនមួយចំនួនដែលនៅក្បែរគ្នានៅក្នុងតំបន់គោលដៅក៏អាចចូលរួមក្នុង ក្លឹបថតរូបនេះបានដែរ។ ក្នុងករណីនោះសាលារៀនមធ្យមសិក្សាធនធានដើរតួជាអ្នកសម្របសម្រួល។ ប្រសិនបើមានសាលារៀនមួយចំនួនកំពុងអនុវត្តក្លឹបថតរូប នាយកសាលានានាដែលពាក់ព័ន្ធ សម្រេចចិត្តដាក់ធនធានរួមគ្នាសម្រាប់ធ្វើសកម្មភាពដូចជា ទស្សនកិច្ចសិក្សា ពិព័រណ៍ថតរូប ។ល។ ការអនុវត្តសកម្មភាពរួមគ្នាអាចមានអត្ថប្រយោជន៍មួយចំនួនដូចជា អាចបញ្ចៀសការធ្វើសកម្មភាពជាន់គ្នា ជាពិសេសករណីដំណើរទស្សនកិច្ចសិក្សា។ ទោះបីយ៉ាងណាក៏ដោយការសម្របសម្រួលក្នុងកម្រិតនេះ ពេលខ្លះអាចជួបបញ្ហាប្រឈម។ នាយកសាលាដែលពាក់ព័ន្ធគួរពិនិត្យមើលកម្រិតចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបថតរូប ពីសាលារៀនផ្សេងទៀត ចម្ងាយរវាងសាលារៀន និងការពេញចិត្តរបស់គ្រូសម្របសម្រួលនៅពេលសម្រេចចិត្តថាតើត្រូវរៀបចំក្លឹបរួមគ្នា ឬធ្វើដាច់ដោយឡែក។ ក្នុងករណីអនុវត្តសកម្មភាពរួមគ្នា គេត្រូវចាត់ចែងថវិកាមួយចំនួនដែលចាំបាច់ សម្រាប់ធ្វើដំណើរសម្របសម្រួលកិច្ចប្រជុំអន្តរសាលា។

### ៤.១.៣. កម្រិតថ្នាក់គោលដៅ

ការចូលរួមនៅក្នុងក្លឹបថតរូប អាចមានដំណើរការល្អប្រសើរ ប្រសិនបើយើងជ្រើសរើសសិស្សដែលមានភាពពេញវ័យ។ នៅពេលសាលាមានបទពិសោធន៍ច្រើនក្នុងការរៀបចំក្លឹបនេះហើយ គ្រូប្រហែលជាអាចធ្វើការសាកល្បងរៀបចំសកម្មភាពទាំងឡាយដែលសមស្របទៅអាយុសិស្ស។ ជាជំហានដំបូងគេបានណែនាំថា ក្លឹបថតរូប គួរផ្តោតទៅលើសិស្សថ្នាក់ទី១០ ឬទី១១ អាស្រ័យទៅលើលទ្ធភាពគ្រូដែលចាប់អារម្មណ៍ក្នុងការធ្វើការជាមួយសិស្ស។

### ៤.១.៤. ការវាយតម្លៃចំណាប់អារម្មណ៍សិស្សនិងការតម្រង់ទិស

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លឹប គួរតែផ្អែកលើការសម្រេចចិត្តដែលត្រូវបានផ្តល់ព័ត៌មានជាមុន។ ក្នុងការវាយតម្លៃចំណាប់អារម្មណ៍សិស្សឱ្យចូលរួមក្នុងក្លឹប គ្រូសម្របសម្រួលជាដំបូងត្រូវផ្តល់ព័ត៌មានណែនាំ ថាតើក្លឹបនេះគឺជាអ្វី? វាអាចត្រូវបានធ្វើឡើងតាមរយៈការពន្យល់ដោយមាត់ទទេទៅកាន់សិស្សក្នុង

ថ្នាក់ ឬការពន្យល់ដោយសរសេរបិទនៅតាមទីធ្លាសាលារៀន ឬទាំងពីររបៀបក៏បាន។ ចំណុចមួយចំនួនដែលត្រូវបានរៀបរាប់នៅក្នុងការណែនាំគួររួមបញ្ចូលនូវចំណុចខាងក្រោម៖

- **វត្ថុបំណង៖** ផ្ដល់បរិយាកាសដល់សិស្សដើម្បីស្វែងយល់បច្ចេកវិទ្យាថ្មីៗ តាមរយៈការប្រើប្រាស់ម៉ាស៊ីនថតរូបឌីជីថល រៀនមូលដ្ឋានគ្រឹះនៃការថតរូប ត្រិះរិះពិចារណាពីការថតរូប អភិវឌ្ឍជំនាញថតរូប និងគំនិតច្នៃប្រតិដ្ឋដទៃទៀត។
- **សកម្មភាព៖** បណ្ដុះបណ្ដាលបច្ចេកទេសជាមូលដ្ឋាន វិភាគរូបភាព ការបង្កើតប្លង់ថតផ្សេងៗគ្នាបង្កើតខ្សែរឿងរូបថត(ខ្សែរឿងរូបភាព) ឬការបង្ហាញពីរូបថត ការរៀបចំពិព័រណ៍បណ្ណាល័យ និងដំណើរទស្សនកិច្ចសិក្សានានា។
- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សធ្វើសកម្មភាព ពីព្រោះពួកគេចង់ធ្វើមិនមែនពួកគេត្រូវបានបង្ខំឱ្យធ្វើនោះទេ។
- **ការចូលរួម៖** សមាជិកនៃក្លឹបគឺតាមរយៈការស្ម័គ្រចិត្ត។
- **ការប្រជុំ៖** មានការប្រជុំជាទៀងទាត់ (ប្រហែល២សប្ដាហ៍ប្រជុំម្ដង) ដើម្បីពិភាក្សាសកម្មភាពដែលបានគ្រោងទុក។ ការប្រជុំ នឹងត្រូវធ្វើឡើងក្រៅម៉ោងសិក្សា ឬនៅពេលដែលសាលាឈប់សម្រាក។

បន្ទាប់ពីការណែនាំនេះ ត្រូវសួរសិស្សថាតើពួកគេមានចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបថតរូបនេះដែរឬទេ ដើម្បីចង្អុលបង្ហាញនូវកម្រិតនៃការចាប់អារម្មណ៍ពួកគេ។ ក្នុងការវាយតម្លៃលើចំណាប់អារម្មណ៍សិស្សសូមប្រើទម្រង់ដែលបង្ហាញនៅក្នុង**ឧបសម្ព័ន្ធទី១**។ ទម្រង់នេះមានសារៈប្រយោជន៍ ពីព្រោះវានឹងការពារមិនឱ្យសិស្សមានការភ័យខ្លាចក្នុងការនិយាយពាក្យ «ព្រម» ឬ «មិនព្រម» ជាពិសេសគ្រូដឹងពីការមិនចំណាប់អារម្មណ៍អាចសម្ដែងពីការមិនគោរពទៅលើគ្រូ។ ទុកពេលឱ្យសិស្ស ១០ទៅ ១៥នាទី ដើម្បីសម្រេចចិត្តដោយខ្លួនឯងមុនពេលបំពេញទម្រង់ និងជូនទម្រង់នោះមកឱ្យគ្រូវិញ។

#### ៤.១.៥. ការបែងចែកភារកិច្ច

នៅក្នុងការប្រជុំក្លឹបលើកដំបូង គ្រូសម្របសម្រួលក្លឹប ត្រូវរៀបចំជ្រើសរើសសមាជិកមួយចំនួនដើម្បីទទួលខុសត្រូវតួនាទីភារកិច្ច។ ការជ្រើសរើសនេះ អាចធ្វើឡើងតាមរយៈការបោះឆ្នោត ឬដោយការលើកដៃ។ តួនាទីក្នុងក្លឹបអាចមានការផ្លាស់ប្ដូររួមមាន (១)ប្រធាន (២)អនុប្រធាន និង(៣)ហេរញ្ញិក។ ប្រសិនបើមានសិស្សច្រើននៅក្នុងក្លឹប (ឧ. ១៥នាក់ ឬច្រើនជាងនេះ) ចាំបាច់ត្រូវមានប្រធានក្រុមមួយសម្រាប់សមាជិក ៣ទៅ ៤នាក់។ ការទទួលខុសត្រូវសម្រាប់តួនាទីនីមួយៗ ត្រូវបានបង្ហាញនៅក្នុង**ឧបសម្ព័ន្ធទី២**។ ការទទួលខុសត្រូវទាំងនេះត្រូវបង្ហាញដល់សមាជិកក្លឹបទាំងអស់ ហើយត្រូវពន្យល់ដោយគ្រូសម្របសម្រួលក្លឹប។ ក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូដែលមានភារកិច្ចទទួលខុសត្រូវលើការងារនេះ ត្រូវមានទំនាក់ទំនងល្អក្នុងការចូលរួមចំណែកជួយដល់សមាជិកក្លឹបដែលបានជ្រើសរើសបំពេញតាមតួនាទីរបស់ពួកគេ។ គ្រូដឹកនាំ ត្រូវចេះផ្ទេរការទទួលខុសត្រូវឱ្យបានច្រើនដល់សិស្ស ពេលពួកគេមានបទពិសោធន៍ក្នុងការបំពេញភារកិច្ចផ្សេងៗនៅអំឡុងឆ្នាំសិក្សានេះ។

### ៤.១.៦. ការកំណត់ផែនការ

សកម្មភាពដំបូងក្លឹបថតរូបគួរធ្វើ គឺការរៀបចំផែនការសកម្មភាពដែលពួកគេស្នើអនុវត្តក្នុងរយៈពេលមួយត្រីមាស។ ទម្រង់ផែនការសកម្មភាពនេះ អាចជួយដល់ដំណើរការសកម្មភាពក្លឹបទៅតាមសប្តាហ៍នៃខែនីមួយៗដូចបានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធទី៣**។ មុនពេលធ្វើផែនការ គ្រូដឹកនាំគួរតែព្យាយាមពិនិត្យមើលសកម្មភាពដែលអាចធ្វើបាន ហើយកំណត់ប្រធានបទមួយ ឬពីរ ដែលក្លឹបនឹងធ្វើក្នុងត្រីមាស។ ឧទាហរណ៍ខ្លះៗ ពីប្រធានបទត្រូវបានផ្តល់ជូននៅផ្នែកក្រោយទៀត។ ឧទាហរណ៍៖ ក្លឹបថតរូបចង់បង្កើតរូបថតជាខ្សែរឿង ឬរបាយការណ៍រូបភាពជាដើម។ សកម្មភាពទាំងនេះនឹងជួយឱ្យសិស្សអភិវឌ្ឍ ការស្រមើស្រម៉ៃ និងគំនិតច្នៃប្រតិដ្ឋពួកគេឱ្យកាន់តែប្រសើរឡើង។ ពួកគេនឹងរៀនធ្វើការងារជាក្រុម។ ជំនាញរចនា និងការធ្វើបទបង្ហាញមានសារៈសំខាន់ណាស់ក្នុងការរៀបចំជាខ្សែរឿងល្អៗ ឬរបាយការណ៍ ដើម្បីចែករំលែកជាមួយសិស្សដទៃទៀត។ សកម្មភាពទាំងអស់ដែលត្រូវរៀបចំសរសេរនៅក្នុងផែនការសកម្មភាព។ ឧទាហរណ៍គំរូមាននៅក្នុងតារាងខាងក្រោម៖

**តារាងទី១ ៖ ការកំណត់ផែនការ**

**ត្រីមាសទី១**

| **សកម្មភាព** | **វិច្ឆិកា** | | | | **ធ្នូ** | | | | **មករា** | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| 1. សកម្មភាពទី១៖ បោះឆ្នោតរៀបចំរចនាសម្ព័ន្ធ និងពិភាក្សាអំពីសកម្មភាពនានា | X | | | | | | | | | | | |
| 2. សកម្មភាពទី២៖ មូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលបច្ចេកទេស | | X | | | | | | | | | | |
| 3. សកម្មភាពទី៣៖ ការពិភាក្សាអំពីរូបភាព | | | X | | | | | | | | | |
| 4. សកម្មភាពទី៤៖ ការបំផុសគំនិត និងរៀបចំផែនការសម្រាប់ថតរូប | | | | X | | | | | | | | |
| 5. សកម្មភាពទី៥៖ ការថតរូបភាព | | | | | X | | | | | | | |
| 6. សកម្មភាពទី៦៖ បង្កើត រូបថតជាខ្សែរឿង (ដាក់រូបថតរួមគ្នានិងបន្ថែមពពុះពាក្យសន្ទនា) | | | | | | X | | | | | | |
| 7. សកម្មភាពទី៧៖ ការធ្វើដំណើរទស្សនកិច្ចសិក្សា និងការធ្វើរបាយការណ៍ | | | | | | | X | X | | | | |
| 8. សកម្មភាពទី៨៖ រៀបចំផែនការពិព័រណ៍ | | | | | | | | | X | | | |
| 9. សកម្មភាពទី៩៖ រៀបចំ និងពិព័រណ៍ | | | | | | | | | | X | | |

### ៤.១.៧. ការកំណត់ធនធាន

ដើម្បីឱ្យក្លឹបមានដំណើរការដោយប្រសិទ្ធភាពត្រូវមានធនធានគាំទ្រ។ ធនធានទាំងនេះរួមមាន សម្ភាររូបវន្តដូចជា កន្លែងប្រជុំ (ឧ. បណ្ណាល័យ ថ្នាក់រៀនដែលទំនេរ ឬទីធ្លាណាមួយ) សម្ភារប្រើប្រាស់បានសម្រាប់ធនធានថ្នាក់រៀនដូចជា កន្ត្រៃ ឬការសម្រាប់ការរចនាសម្លៀកបំពាក់ វេទិកា គ្រឿងតែងវេទិកា ការប្រើប្រាស់ម៉ាស៊ីន

ថតចម្លង សម្រាប់ថតចម្លងអត្ថបទឱ្យសមាជិកក្លឹប ឬធនធានថវិកា។ ធនធាថវិកាត្រូវប្រើសម្រាប់សកម្មភាពជាក់លាក់ដូចខាងក្រោម៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ណាមួយ (សម្រាប់ក្រុមទាំងអស់)
- ផ្ទាំងក្រដាសសម្រាប់គូររូបភាព គូរផែនទី ធ្វើពិព័រណ៍ ការប្រជុំ
- ហ្វឺត ប៊ិកសម្រាប់រៀបចំផ្ទាំងពិព័រណ៍
- ថវិកាសម្រាប់ធ្វើដំណើរទស្សនកិច្ចសិក្សា
- ម៉ាស៊ីនថតរូប និងឧបករណ៍ជំនួយផ្សេងៗសម្រាប់ម៉ាស៊ីនថតរូប(ដូចជាជើងទម្រម៉ាស៊ីនថតរូប,...) ប្រសិនបើមានថវិកា
- ថវិកាផ្សេងៗសម្រាប់គោលបំណងពិសេសនានា
- ផ្សេងៗ

ថវិកាគួរតែរៀបចំក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍសាលាប្រចាំឆ្នាំ ធ្វើឡើងនៅរៀងរាល់ដើមឆ្នាំ។ *ការពន្យល់បកស្រាយអំពីថវិកាមាននៅក្នុងឧបសម្ព័ន្ធទី៤។*

### ៤.២. សកម្មភាពស្នើឡើង

មានសកម្មភាពជាច្រើនដែលក្លឹបអាចរៀបចំ ដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្ស។ សកម្មភាពដែលបានផ្តល់ឱ្យខាងក្រោម គឺគ្រាន់តែឧទាហរណ៍ប៉ុណ្ណោះ។ គ្រូសម្របសម្រួល និងសមាជិកក្លឹបអាចមានគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីអ្វីដែលចង់ធ្វើដើម្បីអនុវត្តភាពច្នៃប្រឌិតតាមរយៈ ការថតរូប។

សកម្មភាពទាំងនោះរួមមាន ការបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃបច្ចេកទេស ការពិភាក្សាពីរូបភាពដែលថត ដោយអ្នកថតរូបល្បីៗចំណាប់អារម្មណ៍នៅក្នុងខ្សែរឿងរូបភាព ឬរបាយការណ៍រូបភាព និងដំណើរទស្សនកិច្ចសិក្សា។ សិស្សគួរតែធ្វើការតាំងពិព័រណ៍រូបភាព ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេ ជាមួយសិស្សដទៃទៀតនៅចុងឆ្នាំនីមួយៗ។

សកម្មភាពទាំងអស់នេះនឹងជួយជំរុញការស្រមើស្រម៉ៃ ការច្នៃប្រតិដ្ឋ និងជំនាញរចនារបស់សិស្ស។ ពួកគេក៏រៀនជំនាញបច្ចេកទេសក្នុងការប្រើប្រាស់ ម៉ាស៊ីនថតរូបឌីជីថលផងដែរ។ តាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ សិស្សទទួលបាននូវចំណេះដឹង ដែលផ្តល់ឱកាសឱ្យពួកគេអនុវត្តសកម្មភាពផ្សេងៗ បន្ថែមលើសកម្មភាពក្លឹបដោយការប្រើប្រាស់ ទូរសព្ទឆ្លាតវៃ។ វាក៏ផ្តល់ឱ្យសិស្សនូវឱកាសក្នុងការគិត និងពិភាក្សាជាមួយគ្រូពីការថតរូប។

ពេលចាប់ផ្តើមអនុវត្តក្លឹបដំបូង ជាការណ៍ល្អប្រសិនបើគ្រូសម្របសម្រួលជាអ្នកដឹកនាំការប្រជុំលើកទី១ ព្រោះសិស្សមិនទាន់មានបទពិសោធន៍ទាក់ទងនឹងការអនុវត្តក្លឹបនេះទេ។ គ្រូត្រូវផ្តល់វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះបច្ចេកទេសថតរូប ការចាប់ប្លង់ដោយម៉ាស៊ីនថតរូបឌីជីថល។ល។ ក្រោយមកទៀត សិស្សត្រូវចូលរួម និងទទួលខុសត្រូវឱ្យបានច្រើន។ ការចូលរួមក្នុងក្លឹប គឺជាការស្ម័គ្រចិត្ត ដូចនេះជាការចាំបាច់គ្រូត្រូវគោរពតាមចំណាប់អារម្មណ៍សិស្ស និងអនុញ្ញាតឱ្យពួកគេលើកឡើងពីប្រធានបទ ឬសកម្មភាពដោយខ្លួនឯង។

### ៤.២.១ ចំណេះដឹងមូលដ្ឋានគ្រឹះនៃការថតរូប

មុនពេលចាប់ផ្តើមថតរូប មានចំណុចសំខាន់ៗជាច្រើនសម្រាប់សិស្សត្រូវដឹងដូចជា ស្គាល់ច្បាស់ពីម៉ាស៊ីនថតរូបឌីជីថល ការចាប់ប្លង់ និងការចាប់យករូបភាព។ គ្រូដឹកនាំគួរតែចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលជាមូលដ្ឋានគ្រឹះដល់សិស្សពីរបៀបកាន់ម៉ាស៊ីនថត ប៊ូតុង និងមុខងារសំខាន់ៗរបស់ម៉ាស៊ីនថតរូប។ គ្រូដឹកនាំគួរតែពន្យល់ពីមុខងារសំខាន់របស់ម៉ាស៊ីនថតដូចជា របៀបប្រើម៉ាក្រូម៉ូដ(Macro mode), ការពង្រីក, កម្រិតពន្លឺ (ISO ការគ្រប់គ្រង ពន្លឺលើវត្ថុដែលយើងផ្តោតទៅលើ) ការកំណត់នាទីថតស្វ័យប្រវត្តិ (Timer) ការដំឡើង ឬបន្ថយពន្លឺរូបភាពទាំងមូល(Exposure)។ គ្រូគួរតែបង្ហាញសិស្សពីរបៀបបញ្ចូលរូបភាពទៅក្នុងកុំព្យូទ័រ និងរបៀបបើកមើលរូបភាពក្នុងកុំព្យូទ័រផងដែរ។

តាមការបណ្តុះបណ្តាលរយៈពេលខ្លីនេះ សិស្សនឹងមានលទ្ធភាពក្នុងការចាប់ប្លង់ និងថតរូបដោយប្រើម៉ាស៊ីនថតឌីជីថល នៅពេលណាដែលពួកគេចង់ប្រើ (នៅផ្ទះ ឬពេលដែលពួកគេធ្វើដំណើរកម្សាន្ត...)។ប្រសិនបើសិស្សមានទូរសព្ទឆ្លាតវៃ ពួកគេក៏មានលទ្ធភាពអនុវត្តការងារក្លឹប និងថតរូបបានដែរតាមរយៈចំណេះដឹងពីការបណ្តុះបណ្តាលនេះ និងចែករំលែកបទពិសោធន៍នេះទៅសមាជិកក្នុងក្លឹបនៅពេលប្រជុំ។ បន្ទាប់ពីការបណ្តុះបណ្តាលរយៈពេលខ្លីនេះសិស្សគួរតែចាប់ផ្តើមលេងល្បែងសិក្សាផ្សេងៗដើម្បីស្គាល់ច្បាស់ពីមុខងារម៉ាស៊ីនថត និងប្លង់ថតរូប។

## ការបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃការថតរូប




គុណសម្បត្តិនៃម៉ាស៊ីនថតប្រភេទ Point-and-Shoot គឺគ្រប់គ្រងមុខងារគ្រប់យ៉ាងក្នុងពេលថតរូប ពីព្រោះវាដំណើរការដោយស្វ័យប្រវត្តិ។ អ្នកត្រូវជ្រើសរើសរូបភាពដែលត្រូវផ្តោត (Subject) និងតុបតែងរូបភាពនោះឱ្យបានស្អាត និងមានរបៀប។ ទោះបីជាម៉ាស៊ីនថតរូបឌីជីថលមានមុខងារស្វ័យប្រវត្តិក្នុងការចាប់ប្លង់រូបភាពយ៉ាងណាក៏ដោយ ក៏តម្រូវឱ្យអ្នកដឹងពីការគ្រប់គ្រងមុខងារចាំបាច់មួយចំនួនផងដែរ។ លើសពីនេះ ការកំណត់មុខងារដោយដៃ (Manual) អាចធ្វើឱ្យយើងថតរូបបានស្អាតជាង។ ប្រសិនបើអ្នកចង់ថត ឬចាប់រូបភាពដែលមានចលនាលឿន ឬតម្រូវការតាមលក្ខខណ្ឌពន្លឺ អ្នកអាចកែសម្រួលមុខងារម៉ាស៊ីនថតរូបដោយដៃ។ ម៉ាស៊ីនថតរូបឌីជីថលទាំងអស់មានមុខងារសម្រាប់ថតរូបផ្សេងៗ ដែលអ្នកអាចជ្រើសរើសដូចជា កីឡា (Sport mode) ពេលព្រះអាទិត្យលិច (Sunset) ខាងក្នុងអគារ (Indoor) ពេលរាត្រី (Night Scene) រូបភាពបែបទេសភាព (Landscape) សត្វ (Animals) ឬពេលបាញ់កាំជ្រួច (Firework)។

## របៀបកាន់ម៉ាស៊ីនថត៖




<u>**ការកាន់ផ្តេក៖**</u> ប្រើដៃស្តាំកាន់ម៉ាស៊ីនថត ហើយដាក់ចង្អុលដៃរបស់អ្នកប៉ះចំទីតាំងនៅខាងលើប៊ូតុងថត។ ប្រើដៃឆ្វេង ដែលមានចង្អុលដៃ និងមេដៃជារាងអក្សរ L ដើម្បីទ្រម៉ាស៊ីនថតរបស់អ្នក។

**<u>ការកាន់បញ្ឈរ</u>៖** សូមកាន់ម៉ាស៊ីនថត ដោយដាក់ប៊ូតុងថតនៅផ្នែកខាងលើ ដើម្បីងាយស្រួលផ្លាស់ប្តូរចលនា។ ខណៈដៃស្តាំរបស់អ្នកនៅផ្នែកខាងលើ ដើម្បីចុចប៊ូតុងថតសូមប្រើដៃឆ្វេងទ្រម៉ាស៊ីនថតដោយរក្សាកែងដៃគៀកនឹងដងខ្លួន។

**របៀបថតរូប៖**

1. ចុចបើកម៉ាស៊ីនថតរូប (ប៊ូតុងបិទ/បើក)
2. បើកម៉ាស៊ីនថតហើយជ្រើសរើសមុខងារសម្រាប់ថតស្របតាមស្ថានភាពជាក់ស្តែង
3. ប្រើអេក្រង់ម៉ាស៊ីនថតដើម្បីមើលរូបភាព (ប្រើមុខងារពង្រីក ឬបង្រួម ឬអ្នកអាចចល័តទីតាំងតាមតម្រូវការ)
4. ចុចប៊ូតុងថតពាក់កណ្តាលដើម្បីតម្រង់ ឬចាប់រូបភាព
5. ចុចប៊ូតុងថតពេញលេញដើម្បីផ្តិតយករូបភាពតែម្តង
6. អ្នកអាចពិនិត្យមើលរូបភាពតាមអេក្រង់ម៉ាស៊ីនថត នៅពេលថតរួច។ សូមពិនិត្យមើល ថាតើអ្នកថតរូបភាពបានច្បាស់ ចាប់ប្លង់បានល្អ មានពន្លឺគ្រប់គ្រាន់ ពណ៌ធម្មជាតិច្បាស់។ល។ ប្រសិនបើអ្នកមិនពេញចិត្តនឹងផ្នែកណាមួយនៃរូបថត សូមលុបវាចោលហើយព្យាយាមថតម្តងទៀត។

**ការរៀបចំរូបថត ៖**

- ពិនិត្យមើលប្លង់ទិដ្ឋភាពដែលត្រូវថតរូបតាមកអេក្រង់ម៉ាស៊ីនថតជាមុនសិន
- ត្រូវពិនិត្យមើលបញ្ហាផ្សេងៗក្នុងផ្ទៃខាងក្រោយ (សំរាម ធុងសំរាម ឬ អំពូលភ្លើងតាមដងផ្លូវ) ហើយព្យាយាមស្វែងរកមុំល្អបំផុតសម្រាប់ថត
- ប្រសិនបើរូបបញ្ឈរ សូមបង្វិលម៉ាស៊ីនថតរបស់អ្នកឱ្យចូលមុំ ៩០°




ការផ្តិតយករូបភាពនៅចំកណ្តាលផ្ទៃរូបថត អាចធ្វើឱ្យអ្នកមានអារម្មណ៍មិនពេញចិត្ត។ ដូច្នេះ អ្នកអាចបង្កើនការពេញចិត្តដោយផ្តិតរូបភាពវត្ថុ ឬអ្វីមួយក្នុងទីតាំងផ្សេងៗគ្នា ឬមួយជៀសវាងការកំណត់រូបភាពវត្ថុនៅចំកណ្តាលផ្ទៃរូបថត។



សិស្សត្រូវចេះប្រើមុខងារជំនួយពិសេសៗ (Special Effects) ដើម្បីបង្កើនគុណភាពរូបភាពដូចជាការកែប្រែគុណភាព*ពន្លឺ ការកុងពន្លឺ* ការថតរូបស-ខ្មៅ និងមុខងារច្នៃប្រតិដ្ឋផ្សេងៗ។

**របៀបថតរូបប្រើមុខងារម៉ាក្រូ (Macro)៖** ថតរូបភាពជិតដូចជាផ្កាជាដើម។ ខាងស្តាំនេះជាlogo មុខងារម៉ាក្រូក្នុងម៉ាស៊ីនថត។







រូបភាពខាងស្តាំបង្ហាញពីរូបភាពដែលថតដោយប្រើ Macro Mode។

**ការកំណត់ Shutter Speed៖** មុខងារនេះ ប្រើសម្រាប់កំណត់រយៈពេលនៃសន្ទះដែលត្រូវបើក ឬបិទដើម្បីផ្តិតយក រូបភាព។ ប្រសិនបើអ្នកថតប្លង់រូបភាពក្នុងស្ថានភាពខ្វះពន្លឺ អ្នកត្រូវកំណត់ Shutter Speed ឱ្យទាប។ ការកំណត់បែបនេះនឹងជួយផ្តិតយករូបភាពព្រាលៗ(Blur)លក្ខណៈសិល្បៈ មួយបែបផងដែរ។ ចំណែកការកំណត់ Shutter Speed កម្រិតខ្ពស់ គឺដើម្បីបង្កករូបភាពវត្ថុដែលមានចលនាលឿន។ *(មុខងារនេះមិនមានចំពោះម៉ាស៊ីនថត Point-and-shoot គ្រប់ប្រភេទនោះទេ)*

**ការកំណត់មុខងារ ISO៖** ISO ជាមុខងារសំខាន់សម្រាប់ការថតរូបឌីជីថល។ អ្នកអាចកំណត់មុខងារ ISO ឱ្យដំណើរការដោយស្វ័យប្រវត្តិបាន។ បើអ្នកចង់ថតរូបភាពក្នុងអគារ ឬបន្ទប់ដោយប្រើប្រាស់ពន្លឺ Flash ចេញពីម៉ាស៊ីនថត ត្រូវកំណត់មុខងារ ISO កម្រិតខ្ពស់ដោយដៃវិញ។ មុខងារកំណត់ ISO ប្រើសម្រាប់កំណត់កម្រិតបញ្ចេញពន្លឺពីម៉ាស៊ីន។ យើងប្រើមុខងារ ISO កម្រិតទាបសម្រាប់ថតទិដ្ឋភាពដែលមានពន្លឺខ្លាំង ហើយប្រើមុខងារ ISO កម្រិតខ្ពស់សម្រាប់ថតរូបក្នុងទិដ្ឋភាព ដែលមិនមានពន្លឺគ្រប់គ្រាន់ និងទីកន្លែងផ្សេងៗទៀតដូចជា វិចិត្រសាល ព្រះវិហារ កន្លែងជប់លៀង ខួបកំណើត ការប្រគំតន្ត្រី សកម្មភាពសម្តែងកីឡាក្នុងសាល...។

**ការណែនាំពីការចាប់ប្លង់រូបភាព៖**

**ការថតរូបទេសភាព(Landscape)៖**



ការថតរូបទេសភាព ចង់បង្ហាញពីចំណុចគួរចាប់អារម្មណ៍នៃទេសភាពណាមួយ។ ឧទាហរណ៍ វាលលំហ ភ្នំ ឆ្នេរសមុទ្រ ឬទេសភាពទីក្រុង។

**គន្លឹះ៖** ដំបូងពិនិត្យមើលទស្សនីយភាពគ្រប់ជ្រុង។ ស្វែងរកវត្ថុអ្វីដែលយើងចាប់អារម្មណ៍។ បើសិនយើងចង់ថតរូបទេសភាពព្រៃភ្នំ ឬខ្ពង់រាប យើងត្រូវថតរូបទម្រង់ផ្តេក។ បើយើងចង់ថតរូបអ្វីមួយដែលមានជំហរខ្ពស់ដូចជា អាគារ ឬដើមឈើខ្ពស់ៗ ត្រូវប្រើទម្រង់បញ្ឈរ និងដាក់ម៉ាស៊ីនថតឱ្យទាប។ នៅពេលថតរូបបែបទេសភាព យើងគួរថតរូបចេញពីជ្រុងផ្សេងៗឱ្យបានច្រើន។

**ការថតរូប មិត្តភក្តិ និងក្រុមគ្រួសារ ៖**

បើអ្នកថតរូបភាពក្នុងព្រឹត្តិការណ៍ណាមួយ សូមថតប្លង់ផ្សេងៗឱ្យបានច្រើន ចាប់យកទិដ្ឋភាពល្អៗ ជៀសវាងការផ្តិតយករូបភាពរំខាននៃផ្ទៃខាងក្រោយ។ នៅពេលដែលអ្នកថតរូបភាពមនុស្សពីរនាក់ ចូរចុចពង្រីកអេក្រង់ម៉ាស៊ីនថត ដើម្បីថតរូបភាព ។



**ការថតរូបជិតលក្ខណៈ Portrait ៖**

ការថតរូប Portrait ជាការថតរូបមនុស្ស ដើម្បីចាប់យករូបភាពដែលស្អាតបំផុតរបស់មនុស្សម្នាក់នោះ។

**គន្លឹះ៖** សូមបញ្ឈរម៉ាស៊ីនថតក្នុងមុំ៩០ដឺក្រេ។ ដើម្បីទទួលបានរូបថត Portrait ដែលស្អាត ត្រូវថតត្រឹមពីក្បាលមកស្មា ឬថតតែផ្ទៃមុខនិងសក់ ហើយសូមផ្តោតទៅលើកែវភ្នែក។

## គន្លឹះចាប់ប្លង់ថតរូបងាយៗ ៤ចំណុចដែលគួរយល់ដឹងដើម្បីថតរូបឱ្យបានស្អាត

១. ចែកប្លង់ថតចែកជាបី (Rule of Third):

ដំបូងអ្នកត្រូវចែកប្លង់ថតជាបីភាគបញ្ឈរ និងជាបីភាគផ្តេក ហើយដាក់វត្ថុ ឬមុខមនុស្ស ដែលជាប្រធានបទសំខាន់នៃរូបភាពរបស់អ្នក នៅលើចំណុចប្រសព្វមួយក្នុងចំណោម ចំណុចប្រសព្វទាំងបួន នៃខ្សែចែកប្លង់នោះ ដើម្បីឱ្យរូបភាពរបស់អ្នកមើលទៅមានភាពទាក់ទាញជាងធម្មតា។ បន្ថែមពីនេះ អ្នកក៏គួរចាប់ប្លង់ដោយដាក់កន្លែងជួបគ្នារវាងផ្ទៃមេឃ និងដីឱ្យស្របទៅនឹងខ្សែបន្ទាត់ចែកប្លង់ផ្តេកជាបីនោះផងដែរ។





២. ចាប់ប្លង់ឱ្យមានភាពស៊ីមេទ្រីគ្នា(Symmetry):

រូបភាពដែលមានភាពស៊ីមេទ្រី គឺជារូបភាពដែលទាក់ភ្នែក គួរឱ្យចង់មើល និងពេលមើលទៅមានលំនឹងល្អ។ ដូច្នេះនៅពេលថតរូប អ្នកអាចព្យាយាមរកប្លង់ណាឱ្យថតចេញមកមានលក្ខណៈជាស៊ីមេទ្រី ពោលគឺ ស៊ីមេទ្រីបែបផ្តេក ឬបញ្ឈរក៏បាន។





៣. ប្រើប្រាស់ខ្សែបន្ទាត់ដើម្បីដឹកនាំភ្នែកអ្នកមើលទៅកាន់រកមុំសំខាន់នៃរូបភាព (Leading Lines):

អ្នកអាចប្រើប្រាស់ខ្សែនៅក្នុងប្លង់ថតរូបរបស់អ្នក ដើម្បីទាក់ទាញភ្នែកអ្នកមើលពីគែមនៃប្លង់នីមួយៗទៅកាន់មុខមនុស្ស ឬវត្ថុ ដែលជាប្រធានបទ(មុំ)សំខាន់ក្នុងរូបភាពរបស់អ្នក។ ខ្សែ ដែលបាននិយាយនោះ អាចជាផ្លូវថ្នល់ ផ្លូវរទេះភ្លើង ផ្លូវដើរ ឬជាអ្វីក៏ដោយ ដែលមានរាងជាបន្ទាត់ ឬខ្សែស្មើរ ដែលអាចឱ្យច្នៃប្រតិដ្ឋប្រើប្រាស់វាបាន។





៤. ប្រើប្រាស់ស៊ុមក្នុងរូបភាពរបស់អ្នល (Frame within Frame):

ចុងបញ្ចប់ អ្នកអាចថតរូប ឬវត្ថុផ្សេងៗ ដែលមានរាងដូចជាគែមស៊ុមរូបថត ដោយដាក់ប្រធានបទសំខាន់ក្នុងរូបថតរបស់អ្នកនៅក្នុងស៊ុមនោះ អាចជាបង្អួចឡាន បង្អួចផ្ទះ ទ្វារ ដើមឈើសង្ខាង ឬវត្ថុអ្វីក៏បានដែលមើលទៅអាចមានរាងចតុកោណកែង ឬ ការ៉េ ជាដើម។





**ថតរូបដែលមានចលនា/ព្រឹត្តិការណ៍កីឡា៖** ពេលថតរូបសកម្មភាពកីឡា អ្នកថតរូបត្រូវរហ័ស។ ក្នុងព្រឹត្តិការណ៍ប្រកួតកីឡាទាំងអស់ អ្នកថតរូបចង់ផ្ដិតយកទិដ្ឋភាពស្អាតបំផុតដែលកំពុងកើតឡើង។



**គន្លឹះ៖** បើកមុខងារថតសកម្មភាពកីឡា (sport mode) ហើយជ្រើសយក Continuous Focus។ អ្នកក៏ត្រូវប្ដូរមុខងារ Single Shot ទៅ Multi Shot ។

អ្នកគួរព្យាយាមចាប់យករូបភាព ក្នុងពេលមានពន្លឺច្បាស់ និងត្រូវចេះទាញយកប្រយោជន៍ពីលក្ខខណ្ឌ បរិយាកាស។ សូមចងចាំពេលថតរូបត្រូវដឹងពីទិសដៅនៃពន្លឺ៖ Front Light (ជាពន្លឺដែលចាំងពីទីតាំងអ្នកថតទៅរូបភាព) ហើយ Backlight (គឺជាលក្ខខណ្ឌដែលពន្លឺចាំងពីក្រោយរូបភាពមកទីតាំងអ្នកថត)។

- **ការអនុវត្តខ្លីៗ៖**

**វត្ថុបំណង៖** ឱ្យសិស្សយកទ្រឹស្តីទៅអនុវត្ត។
**សម្ភារៈ៖** ម៉ាស៊ីនថត និងទូរស័ព្ទឆ្លាតវៃ
**រយៈពេល៖** ៣០-៤៥ នាទី

ក្រោយពីការបណ្តុះបណ្តាលទ្រឹស្តីខ្លីៗដែលផ្តល់ដោយគ្រូដឹកនាំរួច សិស្សនឹងអនុវត្តដោយប្រើម៉ាស៊ីនថតរូបឬទូរសព្ទឆ្លាតវៃ ថតរូបភាពដែលមាននៅជុំវិញសាលារៀន។ សិស្សព្យាយាមប្រើរបៀបថតផ្សេងៗគ្នា (ប្រើ Macro Mode ថតផ្កា ឬ សត្វល្អិត) Sport Mode (ថតកុមារកំពុងរត់លេង), Landscape (ថតអគារសាលា), ...) ហើយពួកគេព្យាយាមកំណត់ជាមួយនឹងពន្លឺ (Front light, back light និងកម្រិត ISO)។ សិស្សក៏អាចសាកល្បងថតប្រើផ្លាស (flash) ក្នុងបន្ទប់បានផងដែរ។ នៅចុងបញ្ចប់ ចំណាប់អារម្មណ៍ពីសមាជិកនៃក្លឹបគឺមានរៀបចំចែករំលែករូបភាពរបស់ពួកគេ និងការប្រៀបធៀបរូបភាពរបស់ពួកគេ។ ដូច្នេះ ពួកគេនឹងអាចរៀនសូត្រពីគ្នាទៅវិញទៅមកបាន។

**វត្ថុបំណង** ៖ រៀនពីរបៀបថតរូបភាពប្លែកៗ
**សម្ភារៈ** ៖ ម៉ាស៊ីនថតរូប និងទូរស័ព្ទឆ្លាតវៃ
**រយៈពេល** ៖ ១ ម៉ោង ទៅ១ម៉ោង៣០នាទី

គ្រូដឹកនាំ បង្ហាញសិស្សនូវរូបភាពផ្សេងៗ។ សិស្សចំណាយពេល ដើម្បីសង្កេតមើលរូបភាព ហើយព្យាយាមស្វែងយល់ពី effect ដែលមាន។

គ្រូផ្តល់ការពន្យល់ងាយៗខ្លីៗ អំពីវិធីដាក់ effect [1] គ្រាន់តែដាក់វត្ថុ ឬរូបភាពនៅចម្ងាយខុសគ្នាពីអ្នកថតរូប។ បន្ទាប់មក សិស្សព្យាយាមបង្កើតរូបភាពដែលមាន effect ដូចគ្នាដោយការថតរូបភាពឱ្យបានច្រើនរហូតដល់ពួកគេទាំងអស់យល់ពីរបៀបធ្វើ effect នេះ។ សិស្សអាចព្យាយាមបង្កើតការបំភាន់ថាក្មេងធំជាងដើមឈើជាដើម។ នៅក្នុងសកម្មភាពនេះ សិស្សនឹងសាកល្បងជាមួយសមាមាត្រទំហំ។ ពួកគេនឹងរីករាយលេងទៅនឹងចម្ងាយថត និងបង្កើតរូបភាពបែបសប្បាយៗ។

[1] ការធ្វើ effect នេះគឺងាយៗ។ ដាក់វត្ថុ ឬរូបដែលត្រូវថតនៅទីតាំងខុសៗគ្នា។ សិស្សត្រូវថតរូបខាងមុខ និងផ្ទៃខាងក្រោយ។ ឧទាហរណ៍ រូបទី១ បុរសម្នាក់កំពុងផ្តុំមិត្តភក្តិរបស់គេ ដែលគេឱ្យអ្នកខាងក្រោយនៅទៅតាំងចំពីមុខអ្នកខាងមុខ។

## «តូច, ធំ» - «ការថតរូបបែបប្លែកៗសប្បាយៗ»










**វត្ថុបំណង** ៖ ឱ្យសិស្សថតរូបនៅខាងក្រៅសាលា

**សម្ភារៈ** ៖ ទូរសព្ទឆ្លាតវៃ

ប្រសិនបើសិស្សទាំងអស់មានទូរសព្ទឆ្លាតវៃ (smart phone) គ្រូអាចដាក់ជាកិច្ចការផ្ទះទៅពួកគេរួចយកមកបង្ហាញនៅពេលប្រជុំបន្ទាប់។ លំហាត់កិច្ចការផ្ទះនេះ សិស្សត្រូវថតរូបភាពចំនួន ៥ ផ្សេងៗគ្នា។ អាចមានសិស្សខ្លះថតរូបភាពបានល្អជាងគេ។ រូបភាពទាំងនោះអាចជារូបភាពរបស់សាច់ញាតិ ផ្ទះ ល្បែងប្រជាប្រិយ សត្វចិញ្ចឹម...

ក្រោយពេលប្រជុំ  សិស្សនឹងអាចចែករំលែករូបភាពរបស់ពួកគេទៅកាន់ក្លឹប។ សកម្មភាពនេះនឹងជួយឱ្យសិស្សស្គាល់គ្នាកាន់តែច្បាស់ ហើយអាចប្រើជាសកម្មភាពកម្សាន្ត   និងធ្វើឱ្យសមាជិកក្លឹបកាន់តែមានភាពស្និតស្នាលដោយធ្វើការជាមួយគ្នា។

**របៀបថត**

ខាងក្រោមនេះអាចជាគំនិត និងគំរូសម្រាប់គ្រូ និងសិស្ស។ ស្លាកសញ្ញាទាំងនេះអាចប្រែប្រួលទៅតាមម៉ាស៊ីនថតរូបនីមួយៗ៖

| Shooting Mode | **ការពិពណ៌នា** | **និមិត្តសញ្ញា** |
|---|---|---|
| Macro | ប្រើសម្រាប់ថតរូបជិត ដូចជារូបមេអំបៅ ផ្កា... |  |
| Portrait | ប្រើសម្រាប់ថតរូបភាពមានផ្ទៃក្រោយព្រាល |  |
| Landscape | ប្រើសម្រាប់ថតរូបលក្ខណៈទេសភាព |  |
| Sport | ប្រើសម្រាប់ថតសកម្មភាពកីឡាផ្សេងៗ |  |
| Night Portrait | ប្រើសម្រាប់ថតរូបភាពនៅពេលពន្លឺខ្សោយ ឬពេលយប់ដោយមានពន្លឺចេញពីកាមេរ៉ា( Flash ) |  |

### ៤.២.២. ការពិភាក្សា អំពីរូបភាព

សិស្សពិភាក្សាស្វែងយល់ និងវិភាគឱ្យបានល្អិតល្អន់លើរូបភាពដែលបានថត។ សិស្សត្រូវពន្យល់ពីអារម្មណ៍តាមរយៈការមើលរូបភាពល្បីៗ ដោយសង្កេតគ្រប់ទិដ្ឋភាពនៅលើរូបភាពទាំងនោះ ហើយបញ្ចេញយោបល់ផ្ទាល់ខ្លួនរបស់ពួកគេ។ ជាការពិត ការយល់ឃើញរបស់មនុស្សម្នាក់ៗលើរូបភាពមួយ តែងមានគំនិតខុសៗគ្នាទៅតាមបទពិសោធន៍ផ្ទាល់ខ្លួន បរិស្ថាន និងចំណេះដឹង។ មានសកម្មភាពជាច្រើនដែលយើងអាចអនុវត្តបានទាក់ទងនឹងរូបភាព និងបច្ចេកទេសថតរូបដូចជា សិស្សប្រមូលគំនិត ការកំណត់ប្រភេទផ្សេងៗនៃរូបភាពដែលចង់ថត ការចែករំលែកនូវអារម្មណ៍ផ្ទាល់ខ្លួនបន្ទាប់ពីមើលរូបភាព ទឹកមុខ និងអារម្មណ៍អ្នកដែលត្រូវថត ហើយស្របពេលគ្នានោះដែរ ពួកគេក៏អាចរៀនពីរបៀបថតរូបលក្ខណៈថតជិត( Portrait )ផងដែរ។ សកម្មភាព និងព័ត៌មានលម្អិតផ្សេងៗជាច្រើនទៀតអាចរកបាននៅ។

**ការពិភាក្សាអំពីរូបភាព**

ជំពូកនេះអាចត្រូវបានបែងចែក ជាសកម្មភាពផ្សេងៗគ្នាជាច្រើន។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗ។

- **ការបំផុសគំនិត៖**

គ្រូសួរសិស្សនូវសំណួរមួយចំនួនដូចជា៖

- តើយើងអាចរករូបភាពនៅឯណា ?
- តើការថតរូបប្រភេទណាខ្លះដែលអ្នកស្គាល់ ?
- តើរូបភាពត្រូវបានប្រើសម្រាប់ធ្វើអ្វីខ្លះ ?
- តើអ្វីដែលធ្វើឱ្យរូបភាពមួយស្អាត ឬមិនស្អាត ?

សិស្សពិភាក្សានៅក្នុងក្រុមតូច និងសរសេរចេញពីគំនិតទាំងអស់ដែលគេមាន ។ បន្ទាប់ពី ២០នាទី នៃការរិះរកគំនិតមក តំណាងម្នាក់នៃក្រុមនីមួយៗនឹងឡើងចែករំលែកពីគំនិតរបស់ពួកគេ។ បន្ទាប់មកទៀត សមាជិកក្នុងក្រុមធំនឹងសំយោគចម្លើយរបស់សំណួរនីមួយៗនៅលើក្រដាសផ្ទាំងធំ។

***ចម្លើយដែលអាចមាន៖***

- **តើយើងអាចរករូបភាពនៅឯណា? កម្រងឯកសារ** ការផ្សព្វផ្សាយពាណិជ្ជកម្ម កាសែត ផ្ទាំងរូបភាព សៀវភៅ ទស្សនាវដ្តី រូបភាពផ្ទាល់ខ្លួនរក្សាទុកនៅផ្ទះ នៅលើអ៊ីនធឺណេត។ល។
- **តើការថតរូបប្រភេទណាខ្លះដែលអ្នកស្គាល់?** ការថតរូបអាជីព ការថតរូបធម្មជាតិ ការថតរូបមនុស្ស ការថតរូបទេសភាព ការថតរូបកសិកម្ម ការថតរូបស្ថាបត្យកម្ម ការថតរូបតាមផ្លូវ ការថតរូបដំណើរកម្សាន្ត ការថតរូបកីឡា ការថតរូបក្នុងស្ទូឌីយោថតរូប ការថតរូបរបាយការណ៍ និងការថតរូបជីវភាពប្រចាំថ្ងៃ។
- **តើរូបភាពត្រូវបានប្រើសម្រាប់ធ្វើអ្វីខ្លះ?** ជាឧបករណ៍ទំនាក់ទំនង ព័ត៌មាន(ដើម្បីបញ្ជូនសារមួយដូចនៅក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មជាដើម) ជាទម្រង់សិល្បៈ ជាការកម្សាន្ត ។ល។
- **តើអ្វីដែលធ្វើឱ្យរូបភាពមួយស្អាត ឬមិនស្អាត?** វាអាចជា ពន្លឺ មុំថត ប្រធានបទ ឬអ្វីផ្សេងទៀតដែលយើងចូលចិត្ត។ សំណួរនេះ គឺមានលក្ខណៈផ្ទាល់ខ្លួន គ្មានចម្លើយត្រូវ ឬខុសនោះទេ។

*<u>ការវិភាគរូបភាព</u>*

**វត្ថុបំណង ៖** សិស្សមើលរូបភាពណាមួយ រួចបង្ហាញចំណាប់អារម្មណ៍ពួកគេទៅសិស្សដទៃ។

**សម្ភារៈ** ៖ រូបភាព ក្រដាស និងប៊ិក

**រយៈពេល** ៖ ៤៥ នាទី - ១ ម៉ោង

**លំហាត់ទី១ ៖**

គ្រូដាក់រូបភាពមួយចំនួន(រូបភាពល្បីៗ)នៅលើតុ។ សិស្សចំណាយពេលដើម្បីមើលរូបភាពផ្សេងៗគ្នា បន្ទាប់មកពួកគេជ្រើសរើសរូបភាពដែលពួកគេពេញចិត្ត។ ជាលក្ខណៈបុគ្គល ពួកគេមានរយៈពេល ៥នាទី ដើម្បីសរសេរអំណះអំណាង ហេតុអ្វីបានជារូបភាពនោះជារូបភាពដែលពួកគេចូលចិត្ត(រួមទាំងអារម្មណ៍ពេលមើលរូបភាពដែលបានជ្រើសរើស)។ សិស្សទាំងអស់ដែលចូលចិត្តរូបភាពតែមួយ ត្រូវដាក់ចូលគ្នានិងចែករំលែកគំនិតជាមួយគ្នា។ បន្ទាប់ពីការពិភាក្សាជាក្រុមរយៈពេល ៥ - ១០នាទី មកអ្នកតំណាងក្រុមនីមួយៗនឹងពន្យល់ដល់ក្លឹបថា តើមានអំណះអំណាងសំខាន់អ្វីខ្លះ ដែលនាំឱ្យពួកគេពេញចិត្ត និងមិនពេញចិត្តរូបភាពណាមួយជាងគេ?

គ្រូត្រូវពន្យល់សិស្សថាមិនមានចម្លើយត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ។ មនុស្សតែងតែមានអារម្មណ៍ខុសគ្នាសម្រាប់មនុស្សម្នាក់ៗ។ វាជាការសំខាន់ណាស់ដែលសិស្សបង្ហាញនូវអំណះអំណាងពួកគេឱ្យបានច្បាស់។

នៅចុងបញ្ចប់ គ្រូសួរសិស្សថា តើពួកគេដឹងពីរឿងអ្វីខ្លះនៅពីក្រោយរូបភាពទាំងនោះដែរឬទេ? គ្រូនឹងពន្យល់ពីរឿងរ៉ាវខ្លះៗនៃរូបភាពដែលបានបង្ហាញ។ សំណួរបន្ថែមអាចពិភាក្សាជាក្រុមតូចៗ។

**លំហាត់ទី២៖**

គ្រូបង្ហាញរូបភាពមួយចំនួន ហើយសិស្សត្រូវការវិភាគលក្ខណៈបច្ចេកទេសទាំងអស់ដែលមាននៅក្នុងរូបភាពទាំងនោះជាក្រុមតូចៗ។ នៅពេលវិភាគរូបភាព សិស្សត្រូវកំណត់ប្រភេទរូបភាព (ដូចជាទេសភាព រូបភាពមនុស្ស កីឡា...) និងវិភាគផ្នែកផ្សេងៗទៀតទាក់ទងនឹងរូបភាពដូចជា ប្រធានបទ (តើអ្នកថតរូបចង់បង្ហាញ និងចែករំលែកពីអ្វី?) តើអ្វីដែលធ្វើឱ្យអ្នកមិនពេញចិត្តនៅលើរូបភាព? សិស្សក៏ត្រូវផ្តោតលើពន្លឺ (បរិយាកាសក្តៅ ឬត្រជាក់) ទីតាំងផ្នែកសំខាន់នៃរូបភាពដូចជាមនុស្ស(ចំនុចកណ្តាល ឬមិនមែន) មុំថត។

សំណួរបន្ថែមទៀត អាចពិភាក្សាគ្នានៅក្នុងក្រុមតូច៖



- តើមានចំណាប់អារម្មណ៍ ឬសារអ្វីដែលលេចចេញពីរូបភាព?
- តើសារដែលអ្នកថតរូបចង់បង្ហាញ មានភាពច្បាស់លាស់ដែរឬទេ? តើសារនេះធ្វើឱ្យរូបភាពកាន់តែទាក់ទាញឬអត់?
- តើមានទិដ្ឋភាពអ្វីខ្លះនៃរូបភាពដែលមានភាពលេចធ្លោ និងបន្ថែមតម្លៃដល់រូបភាព? អ្វីដែលធ្វើឱ្យរូបភាព មិនទទួលបានការចាប់អារម្មណ៍?
- តើអ្នកមានអារម្មណ៍យ៉ាងណា ពេលមើលរូបភាពនេះ?

**រូបភាពគំរូ៖** គ្រូអាចបន្ថែមរូបភាពផ្សេងៗទៀត (រូបភាព ពីលំហាត់ទី១ និងទី២ ប៉ុន្តែត្រូវតែខុសៗគ្នា)។ រូបភាពបាតុករមិនស្គាល់អត្តសញ្ញាណម្នាក់ ថតដោយលោក Jeff Widener ឆ្នាំ 1989

**__ការពិពណ៌នាខ្លីៗ__** ៖ បុរសម្នាក់ឈរនៅមុខជួររថក្រោះនៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ១៩៨៩ នៅពេលព្រឹកបន្ទាប់ពីយោធាចិនបានបង្ក្រាបការតវ៉ារបស់បាតុករនៅទីលានធានអានមេន ឆ្នាំ១៩៨៩ ដោយប្រើកងកម្លាំងទាហាន។ រថក្រោះបានបើកឆ្លងកាត់ ហើយបុរសនោះគាត់បានបន្តរាំងពួកគេដោយអហិង្សា។ ហេតុការណ៍នេះត្រូវបានថត និងផ្សព្វផ្សាយទូទាំងពិភពលោក។

**«ខ្ញុំបានបង្ហូរទឹកភ្នែក និងរួមស្លាប់ជាមួយកងកម្លាំងរបស់ខ្ញុំដែលកើតក្នុងសង្គ្រាម ដើម្បីជួយក្មេងជំនាន់ក្រោយ»**



## «ក្មេងស្រី ម៉ាឡាហ្គាស៊ី ដើរក្រោមដើម Baobab»



## កូនប្រុសកសិករម្នាក់បានបញ្ចប់ការសិក្សា



**«ចលនាកម្មករដែលគ្មានដីធ្លី»** ថតដោយលោក Luiz Vasconcelos ឆ្នាំ2009

**ការពណ៌នាខ្លីៗ៖** ស្ត្រីម្នាក់ពរកូនព្យាយាមរារាំងកងកម្លាំង ដើម្បីការពារសហគមន៍ និងដីរបស់ពួកគេ។ រូបភាពនេះត្រូវបានគេថតនៅទីក្រុង Manaus ប្រទេសប្រេស៊ីល។



**«ជនអន្តោប្រវេសន៍ម្នាក់បានស្លាប់នៅលើឆ្នេរហ្សាហារ៉ា (ក្រុងកាឌីស ប្រទេសអេស្ប៉ាញ )»** ថតដោយលោក Javier Bauluz, ឆ្នាំ 2000។ លោក Javier Bauluz បានឈ្នះពានរង្វាន់ Pulitzer សម្រាប់រូបភាពល្បីល្បាញនេះ។ រូបភាពនេះបង្ហាញភ្ញៀវទេសចរទាំងពីរនាក់អង្គុយលេងនៅឆ្នេរសមុទ្រជាប់នឹងសាកសពជនអន្តោប្រវេសន៍។



**«កូនក្មេង និងសត្វត្មាត»** ថតដោយលោក Kevin Carter ឆ្នាំ ១៩៩៣ ។



**ការពណ៌នាខ្លីៗ៖** ពេលធ្វើដំណើរទៅប្រទេសស៊ូដង់ លោកខាត់ធ័រ (Carter) បានថតរូបកូនក្មេងអត់ឃ្លានម្នាក់នេះដែលព្យាយាមវារទៅមណ្ឌលផ្តល់ចំណីអាហារស្របពេលដែលសត្វត្មាតចុះមកក្បែរ (ត្មាតរង់ចាំកូនក្មេងនោះស្លាប់ ហើយនឹងក្លាយជាចំណីរបស់វា)។ លោក Carter បានរាយការណ៍ថា លោកបានថតរូបនោះដោយសារនេះជា **«ការងាររបស់លោក»** ហើយក៏ចាកចេញទៅ។ គេបានហាមគាត់មិនឱ្យប៉ះពាល់កុមារនោះទេ ដោយសារខ្លាចជំងឺឆ្លង។ គាត់បានធ្វើអត្តឃាតខ្លួនឯងនៅ៣ខែ បន្ទាប់ពីគាត់បានឈ្នះរង្វាន់ Pulitzer ដោយសាររូបភាពមួយនេះ។

**«ក្មេងស្រីអាហ្វហ្គានីស្ថាន»** ថតដោយលោក Steve MC Curry, ឆ្នាំ១៩៨៤



**ការពិពណ៌នាខ្លីៗ៖** រូបភាពនេះ គឺជារូបភាពមួយដែលល្បីល្បាញបំផុតនៅលើពិភពលោក។ Sharbat Gula ជាក្មេងស្រីអាហ្វហ្គានីស្ថានម្នាក់ ដែលកំពុងរស់នៅជាជនភៀសខ្លួននៅក្នុងប្រទេសប៉ាគីស្ថាន ក្នុងអំឡុងពេលកាន់កាប់របស់សូវៀតនៅអាហ្វហ្គានីស្ថាន នៅពេលដែលនាងត្រូវបានគេថតរូប។ រូបភាពនេះ បានធ្វើឱ្យគេស្គាល់នាងនៅពេលដែលវាត្រូវបានបង្ហាញនៅលើក្របនៃទស្សនាវដ្តី National Geographic Magazine កាលពីខែមិថុនា ឆ្នាំ ១៩៨៥ ពេលដែលនាងមានអាយុប្រហែលជា ១២ ឆ្នាំ។

- **<u>ការអនុវត្ត ៖</u>**

**វត្ថុបំណង៖** សិស្សនឹងបង្ហាញអារម្មណ៍ និងបញ្ជូនសារមួយតាមរយៈរូបភាព
**សម្ភារៈ៖** ម៉ាស៊ីនថតរូប / ទូរស័ព្ទឆ្លាតវៃ
**រយៈពេល៖** ៤៥ នាទីសម្រាប់ហ្គេមនីមួយៗ

សិស្សយករូបភាពមកពីផ្ទះ (កាសែត កម្រងឯកសារ សៀវភៅ ។ល។ )។ ដោយវិភាគរូបភាពផ្សេងៗគ្នា សិស្សនឹងបង្ហាញពីអារម្មណ៍ផ្សេងៗដែលអាចផុសឡើងនៅពេលដែលសម្លឹងមើលរូបភាព។

- **ការថតរូបបែប Communication/ information**

សិស្សបង្កើតជាក្រុមការងារតូចៗ ហើយស្វែងរកសារផ្សេងៗពីរូបភាពតាមដែលអាចធ្វើទៅបាន។ គ្រូត្រូវផ្ដល់ឱ្យក្រុមនីមួយៗនូវប្រធានបទជាក់លាក់មួយដើម្បីថត។ ឧទាហរណ៍សិស្សនឹងត្រូវថតរូបបែប Communication/ Information ដែលផ្ដល់សារដូចខាងក្រោម:

- ការសុំការអនុញ្ញាតដើម្បីបញ្ចេញមតិ
- ការនិយាយ «លាគ្នា»
- ការគំរាមកំហែងដល់នរណាម្នាក់
- «ការជក់បារីគឺមិនល្អសម្រាប់សុខភាព»
- «ក្មេងៗត្រូវស្ដាប់គ្រូ»
- «ការផឹកទឹកជួយឱ្យសុខភាពល្អ»
- ...សិស្សត្រូវស្វែងរកបន្ថែមទៀត

- **ការថតរូបបង្ហាញពីអារម្មណ៍**

សិស្សធ្វើការជាក្រុមតូចៗ ហើយប្រើតែភាសាកាយវិការដើម្បីបង្ហាញអារម្មណ៍។ ការថតរូបបង្ហាញពីអារម្មណ៍អាចធ្វើទៅបានដោយមើលតែទឹកមុខប៉ុណ្ណោះ។ ដូច្នេះ សិស្សនឹងរៀនថតរូបបែប Portrait។ ការណែនាំពីការថតរូបបែប Portrait អាចរកបាននៅ**ការពន្យល់ខាងលើ។**

ដំបូង គ្រូគួរតែឱ្យសិស្សបំផុសគំនិត ដើម្បីសរសេរពីអារម្មណ៍របស់ពួកគេនៅលើផ្ទាំងរូបភាពធំមួយ។ អារម្មណ៍មានពីរប្រភេទគឺ អារម្មណ៍វិជ្ជមាន និងអវិជ្ជមាន។ គ្រូគួរតែចែកបណ្ណជា ២ ជួរ ។ ខាងក្រោមនេះគឺជាគំនិតបន្ថែមពីអារម្មណ៍ដែលសិស្សអាចទទួលយកបាន៖

អារម្មណ៍វិជ្ជមាន

- សប្បាយរីករាយ
- ស្រឡាញ់
- សើច
- ចង់ដឹងចង់ឃើញ
- ក្លាហាន
- ការអត់ធ្មត់
- ...



អារម្មណ៍អវិជ្ជមាន

- ការភ័យខ្លាច
- បារម្ភ
- ភ្ញាក់ផ្អើល
- ឈឺចាប់
- មិនចេះអត់ធ្មត់ ខ្វះភាពអត់ធ្មត់
- ច្រណែន
- ខ្ជិល
- ប្រចណ្ឌ
- ...




### ៤.២.៣. ការបង្កើតខ្សែរឿងរូបភាព

ខ្សែរឿងរូបភាព គឺជាប្រភេទរឿងដោយប្រើរូបភាពផ្សេងៗទាក់ទងគ្នា និងពាក្យសំដីសន្ទនាក្នុងពពុះ។ ជាធម្មតា ខ្សែរឿងរូបភាពអាចបង្កើតឡើងទាក់ទងនឹងការអប់រំខ្លីៗ។ សកម្មភាពទាំងនេះ គឺជាការងារមួយដ៏ល្អដើម្បីធ្វើឱ្យសិស្សមានការអភិវឌ្ឍការស្រមើស្រមៃ និងភាពច្នៃប្រឌិតឱ្យកាន់តែទូលំទូលាយ។ ជាការពិត សិស្សត្រូវប្រឌិតខ្សែរឿងរូបភាពណាមួយ ត្រូវធ្វើការជាក្រុម សម្តែងតួ បង្កើតឈុតឆាកសម្រាប់ថតរូបភាព ហើយចុងក្រោយតែងជាអត្ថបទសម្តែង។ ទាំងនេះ គឺជាសកម្មភាពល្អមួយដែលជួយអភិវឌ្ឍជំនាញរបស់សិស្សឱ្យបានពេញលេញ។ ក្រៅពីការបង្កើតសាច់រឿង និងថតប្លង់រឿង សិស្សត្រូវប្រមូលរូបភាពទាំងអស់មកតម្រៀប ហើយបន្ថែមការសន្ទនាទៅលើរូបភាពទាំងនោះ ដើម្បីធ្វើឱ្យសាច់រឿងមានភាពរស់រវើក។ សិស្សអាចជ្រើសរើសរូបភាព និងពពុះសម្ដីសន្ទនាដាក់រួមគ្នានៅលើក្រដាស ឬដោយប្រើកុំព្យូទ័រ។ មួយវិញទៀត អំឡុងពេលថតរូប សិស្សអនុវត្តចំណេះដឹងផ្នែកថតរូប ដើម្បីថតឱ្យបានល្អបំផុតដោយផ្អែកលើបរិយាកាសពេលថតខាងក្នុង ឬខាងក្រៅអគារ (Indoor or Outdoor) លក្ខខណ្ឌអាកាសធាតុ(មានដូចជា ពន្លឺថ្ងៃ ពពក ...) និង Effect ដែលពួកគេចង់បាន។ សកម្មភាពនេះមានគោលបំណងជួយឱ្យសិស្សបង្កើនចំណាប់អារម្មណ៍ក្នុងការច្នៃប្រឌិត។

## បង្កើតខ្សែរឿងរូបភាព

**វត្ថុបំណង** ៖ អភិវឌ្ឍគំនិតច្នៃប្រឌិតសិស្ស និងធ្វើឱ្យពួកគេគ្រប់គ្រងពីជំហាននីមួយៗនៃការផលិតខ្សែរឿងរូបភាព
**សម្ភារៈ** ៖ ក្រដាស, ប៊ិក, ម៉ាស៊ីនថតរូប, កុំព្យូទ័រ
**ពេលវេលា**៖ ប្រជុំ ២ ឬ ៣ ដង

ការបង្កើតខ្សែរឿងរូបភាព ជាសកម្មភាពរីករាយសម្រាប់សិស្ស។ តាមពិតសកម្មភាពនេះនឹងធ្វើឱ្យមានការច្នៃប្រឌិតកាន់តែទូលំទូលាយ។ សិស្សនឹងត្រូវបង្កើតខ្សែរឿងដែលមានរូបភាពតាមលំដាប់លំដោយពីដើមដល់ចប់។ ដើម្បីបង្កើតខ្សែរឿងរូបភាព សិស្សចាំបាច់ត្រូវគោរពតាមជំហានមួយចំនួន។ ប្រសិនបើសមាជិកនៃក្លឹបមានចំនួនច្រើន គ្រូអាចសម្រេចចិត្តបង្កើតជាក្រុមតូចៗ ចំនួន ២ក្រុម ដោយផលិត ២ រឿងផ្សេងគ្នា។

នៅក្នុងខ្សែរឿងរូបភាព វាមានសារៈសំខាន់ណាស់ដែលរូបភាពមានលក្ខណៈគួរឱ្យចាប់អារម្មណ៍តាមដែលអាចធ្វើទៅបាន។ តាមវិធីនេះ ពពុះពាក្យសន្ទនា (Word Bubble) នឹងត្រូវបានបន្ថែមទៅលើរូបភាព។ ជាការល្អ ខ្សែរឿងរូបភាពមួយ គួរមានរូបភាពជាមធ្យម ១៦ រូបភាព។

**ជំហានទី១ ៖ ការបង្កើតរឿង**

សិស្សត្រូវតែប្រមូលគំនិតអំពីរឿងខ្លីដូចជា ប្រធានបទ តួអង្គ ការរៀបចំប្លង់ និងអត្ថបទដែលត្រូវបញ្ចូល។ សិស្សត្រូវប្រយ័ត្នក្នុងការបង្កើតរឿងខ្លីៗ ដែលមិនមានលំដាប់លំដោយត្រឹមត្រូវ និងមិនគួរវែងពេកនោះទេ។ ពួកគេចាំបាច់ត្រូវតែព្រាងជាមុនសិន។ នៅពេលដែលសាច់រឿងត្រូវបានសរសេរ និងមានភាពច្បាស់លាស់ហើយ សិស្សចាំបាច់ត្រូវសំរេចថាអ្នកណានឹងដើរតួជាតួអង្គនីមួយៗនៅក្នុងរឿង។

ជំហានបន្ទាប់ គឺត្រូវកាត់សាច់រឿងជាផ្នែកៗ។ ផ្នែកនីមួយៗត្រូវមានរូបភាពតំណាងឱ្យសាច់រឿង។

សិស្សត្រូវពិភាក្សា និងធ្វើការជាក្រុមដើម្បីផលិតខ្សែរឿងរូបភាពល្អមួយ។

**ជំហានទី២ ៖ ការរៀបចំផែនការថតរូប**

សិស្សត្រូវរៀបចំផែនការថតរូប។ ទាំងនេះរួមបញ្ចូលទាំងការរៀបចំឈុតឆាក សំលៀកបំពាក់តួអង្គប្រសិនបើចាំបាច់។ សិស្សត្រូវធ្វើរូបតំណាង (គំនូរព្រាង) នៃរូបភាពនីមួយៗ។ របៀបនេះ សិស្សនឹងមើលឃើញពីភាពងាយស្រួលសម្រាប់រៀបចំប្លង់ និងឆាកសម្រាប់ថត។ ប្រការនេះអាចឱ្យសិស្សធ្វើបញ្ជីត្រួតពិនិត្យដើម្បីប្រាកដថាពួកគេមិនភ្លេចចំណុចណាមួយនោះទេ។

សិស្សត្រូវសម្រេចចិត្តថា តើការថតរូបភាពប្រភេទណាដែលពួកគេចង់បាន សម្រាប់ប្រើក្នុងរូបភាពនីមួយៗ (រូបភាព Portrait រូបភាពផ្ទាំងធំៗ)។ ការកំណត់នៅក្នុងម៉ាស៊ីនថតទាំងអស់ ត្រូវអនុវត្តនៅជំហាននេះដូចជា Exposure ចលនា ការចាប់ទីតាំង មុំថត...។

**ជំហានទី៣ ៖ ការថតរូបភាព**

ទីបំផុត ដល់ពេលត្រូវថតរូបហើយ!

វាដល់ពេលដែលសិស្សត្រូវដើរតាមផែនការ និងឯកសារជំនួយផ្សេងៗយកមកថតចេញជារូបភាព។ ផែនការ និងគន្លឹះផ្សេងៗជួយឱ្យសិស្សថតរូបបានល្អ ប៉ុន្តែពួកគេក៏មានសេរីភាពក្នុងការផ្លាស់ប្តូរការកំណត់ប្លង់ដែលត្រូវថត បើមានគំនិតថ្មីណាមួយ។ សិស្សគួរតែថតរូបឱ្យបានច្រើនតាមដែលអាចធ្វើបានដោយមានមុំថត និងទីតាំងខុសៗគ្នា។

សិស្សដែលជាតួអង្គម្នាក់ៗ ត្រូវតែធ្វើសកម្មភាព បង្ហាញទឹកមុខ និងអារម្មណ៍ តាមរបៀបដែលត្រូវសម្តែងរបស់តួអង្គនោះ។ សិស្សដែលមិនមែនជាតួអង្គ អាចដើរតួជាអ្នកប្រឹក្សាយោបល់ក្នុងការជួយសិស្សដែលជាតួអង្គសម្តែងដើម្បីឱ្យពួកគេដាក់អារម្មណ៍តាមសាច់រឿង។

**ជំហានទី៤ ៖ ប្លង់**

បន្ទាប់ពីថតរូបហើយ ត្រូវតែប្រាកដថាប្លង់ទាំងអស់ដែលត្រូវសាច់រឿងបានថតចប់សព្វគ្រប់។ សិស្សត្រូវជ្រើសរើសរូបភាពនៅលើកុំព្យូទ័រដែលជារូបភាពល្អបំផុតតំណាងឱ្យផ្នែកនានានៃខ្សែរឿង។ រូបភាពដែលសម្តែងនិងល្អបំផុតគួរជ្រើសរើសដោយក្រុមរបស់គេ។

ដំហានចុងក្រោយ  សិស្សនឹងដាក់រូបភាពជាមួយគ្នាហើយបន្ថែមពពុះសន្ទនាតូចៗចូលដើម្បីឱ្យសាច់រឿងងាយយល់។ លើសពីនេះទៅទៀតសិស្សអាចបន្ថែមព័ត៌មានលម្អិតអំពីពេលវេលាដូចជា ព្រឹកនេះ ពេលថ្ងៃត្រង់ ពេលយប់ ថ្ងៃបន្ទាប់ មួយសប្តាហ៍បន្ទាប់ពី... ប្លង់អាចធ្វើដោយសរសេរពពុះសន្ទនានៅលើក្រដាស រួចបិតលើរូបភាព ឬ វាយអក្សរបញ្ចូលដោយកុំព្យូទ័រ ប្រសិនបើសិស្សអាចធ្វើបាន។




### ៤.២.៤. ទស្សនកិច្ចសិក្សា

ក្លឹបថតរូបនេះ  ផ្តល់ឱកាសឱ្យសិស្សស្វែងយល់ពីកន្លែងស្អាតៗ  គួរចាប់អារម្មណ៍ផ្សេងៗដូចជាទីរួមខេត្ត ឬទីប្រជុំជនណាមួយជាដើម។ ទីកន្លែងសាមញ្ញមួយអាចមើលឃើញប្លែកៗគ្នា  តាមរយៈរូបភាពផ្សេងៗដែលឱ្យដោយម៉ាស៊ីនថតរូប។ សិស្សអាចព្យាយាមរកមើលប្លង់នៅជុំវិញខ្លួន ដោយភ្នែកទទេដើម្បីស្វែងរកប្លង់ថតថ្មីៗ ដែលពួកគេមិនបានឃើញពីមុនមក។ ជាការពិត មានកន្លែងក្នុងស្រុកជាច្រើន  អាចជាកន្លែងដែលគួរឱ្យចាប់អារម្មណ៍សម្រាប់ការចាប់ប្លង់ ឧទាហរណ៍ ស្ពាន មាត់ទន្លេ  សារមន្ទីរ វត្តភ្នំ អង្គរវត្ត។ល។ សមាជិកក្លឹបនេះនឹងត្រូវទៅទស្សនាកន្លែងផ្សេងៗក្នុងឆ្នាំសិក្សា  ធ្វើសកម្មភាពសប្បាយៗ និងថតរូបធ្វើជារបាយការណ៍ក្លឹប។

## ការធ្វើដំណើរទស្សកិច្ចសិក្សា

ក្លឹបថតរូប ត្រូវធ្វើដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងរកតំបន់ថ្មីៗ ។ ឧទាហរណ៍៖  នៅខេត្តកំពង់ចាមមានកន្លែងជាច្រើនដែលល្អសម្រាប់ការអនុវត្តការថតរូបនេះដូចជា  ប៉មបារាំងបុរាណ  ស្ពានឫស្សី  មាត់ទន្លេកោះប៉ែន ប្រាសាទវត្តនគរបាជ័យ ឬភ្នំប្រុសភ្នំស្រី (សម្រាប់ទេសភាពស្រស់ស្អាត) ។ សម្រាប់សកម្មភាពដែលបានស្នើទាំងអស់របស់សិស្ស អាចប្រើម៉ាស៊ីនថតក៏បាន ឬ ទូរសព្ទឆ្លាតវៃក៏បាន។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃសកម្មភាពមួយចំនួន៖

- **ការប្រមាញ់រូបភាព**

សិស្សនឹងថតរូបភាពពីប្រធានបទ ជាក់លាក់មួយដែលគ្រូដាក់ឱ្យ។ គ្រូបង្កើតក្រុមតូចៗហើយផ្តល់នូវប្រធានបទផ្សេងៗគ្នា សម្រាប់ក្រុមនីមួយៗ។ យោងទៅតាមប្រធានបទរបស់ពួកគេ សិស្សត្រូវថតរូបជាច្រើនតាមដែលពួកគេអាចធ្វើបាន។ គ្រូត្រូវកំណត់ពេលវេលាមួយដើម្បីទទួលយករូបភាព (ឧទាហរណ៍ យូរបំផុត ៣០នាទី)។ បន្ទាប់ពីបានរូបភាព ពេលត្រឡប់ទៅសាលារៀនវិញ ក្រុមរបស់ពួកគេចាប់ផ្តើមមើលរូបភាពដែលថតបាន។ ក្រុមនីមួយៗនឹងធ្វើបទបង្ហាញពីរូបភាពដ៏ស្រស់ស្អាត របស់ពួកគេទៅកាន់ក្លឹប។ បទបង្ហាញអាចធ្វើឡើងដោយ PowerPoint ការបញ្ចាំងស្លាយ ផ្ទាំងរូបភាពច្នៃប្រតិដ្ឋ ឬឯកសារបោះពុម្ព។ សកម្មភាពនេះអាចប្រែក្លាយទៅជាការប្រកួតប្រជែងមួយដែលមានរូបភាពល្អបំផុត បទបង្ហាញល្អបំផុត និងមានអ្នកចាប់អារម្មណ៍ច្រើនជាងគេ ដោយយោងតាមប្រធានបទនីមួយៗ។ រង្វាន់អាចផ្តល់ឱ្យសម្រាប់ក្រុមដែលទទួលបានជោគជ័យបំផុត ។

**គំនិតខ្លះៗដែលជាប្រធានបទ៖** *ស្ថាបត្យកម្ម រាងធរណីមាត្រ មនុស្សធ្វើការងារ, ធម្មជាតិនៅតាមទីក្រុង, ការដឹកជញ្ជូន (ប្រភេទរថយន្តផ្សេងៗ), ពណ៌ជាក់លាក់ណាមួយ ...*

- **ល្បែង «ខ្ញុំជាអ្នកស៊ើបអង្កេត» ៖**

ស្រដៀងទៅនឹងការថតរូបវិចិត្រសាលដែរ ខុសត្រង់តែល្បែងខ្ញុំជាអ្នកស៊ើបអង្កេតនេះខ្លីជាង ហើយមានលក្ខណៈស្វាហាប់ជាង។ គ្រូផ្តល់ប្រធានបទ ហើយសិស្ស (ឬសិស្សជាក្រុមតូចៗ) ត្រូវតែជាអ្នកទីមួយដែលថតរូបតាមប្រធានបទជាក់លាក់ ហើយត្រឡប់មករកគ្រូវិញដោយមានរូបភាពច្បាស់ជាងគេ។ ប្រសិនបើរូបភាពព្រិលមិនច្បាស់គឺមិនត្រូវបានរាប់បញ្ចូលទេ។ នេះជាសកម្មភាពភាពសប្បាយរីករាយមួយ សម្រាប់សិស្សក្នុងការអនុវត្ត ឱ្យពួកគេរត់តាមទីធ្លា និងការព្យាយាមរករូបភាពដែលល្អបំផុត លឿនបំផុតត្រឡប់មកវិញ។

**គំនិតខ្លះដែលជាប្រធានបទ៖** *ខ្ញុំជាអ្នកស៊ើបអង្កេត ឆ្កែមួយក្បាល ឆ្មាមួយក្បាល សត្វបង្គួយមួយក្បាល ទូកមួយ ទង់ជាតិមួយ កុមារជិះកង់ម្នាក់ ម៉ូតូមានគ្នាជិះ ៣ នាក់ ការតម្លៃរ៉ឺម៉កកង់បី ពពកមួយដែលមើលទៅមានរាងជាអ្វីមួយ (ធ្វើឱ្យការស្រមើស្រម៉ៃរបស់អ្នកដំណើរការ) ស្រមោលមនុស្សម្នាក់លេងកីឡា ភេសជ្ជៈ អាហារ (ការចម្អិនអាហារ) មនុស្សចាស់...*

- **របាយការណ៍រូបថត**

របាយការណ៍រូបថតទាក់ទងនឹងព្រឹត្តិការណ៍ណាមួយ។ វាអាចទាក់ទងនឹងដំណើរទស្សនកិច្ចសិក្សារបស់ក្លឹបព្រឹត្តិការណ៍ជាតិ ឬព្រឹត្តិការណ៍សាលារៀន។ ក្លឹបមួយនេះអាចចូលទៅធ្វើទស្សនកិច្ចនៅតាមតំបន់រមណីយដ្ឋាន ឬទីប្រវត្តិសាស្ត្រដែលនៅជិតៗ និងថតរូបភាពធ្វើជារបាយការណ៍។ ទាំងនេះ នឹងមិនត្រឹមតែបង្កើនចំណេះដឹងដល់សិស្សអំពីទីកន្លែងក្នុងស្រុកប៉ុណ្ណោះទេ វាក៏អាចឱ្យពួកគេអភិវឌ្ឍជំនាញសរសេរផងដែរ។ ពេលអ្នកទៅទស្សនានៅកន្លែងណាមួយ អ្នកនឹងទទួលបានរូបភាពជាច្រើន ហើយធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីចែករំលែកព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍ទៅសិស្សដទៃទៀត។ សិស្សក៏អាចសម្ភាស ដើម្បីប្រមូលព័ត៌មានផងដែរ។ របាយការណ៍រូបថតអាច សម្រេចបានតាមរយៈការបង្កើតផ្ទាំងរូបភាពប្រតិដ្ឋ ឯកសារសំណេរដោយដៃ ឬឯកសារសំណេរដោយកុំព្យូទ័រ។

### ៤.២.៥. ការរៀបចំការតាំងពិព័រណ៌

ក្លឹបថតរូបគួរតែរៀបចំការតាំងពិព័រណ៌យ៉ាងតិចណាស់ម្តងក្នុងមួយឆ្នាំសិក្សា។ ជាទូទៅ នៅចុងបញ្ចប់នៃត្រីមាសនីមួយៗ សិស្សអាចតាំងពិព័រណ៌រូបថតនៅក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀនរបស់ពួកគេ ពីការងារដែលពួកគេបានធ្វើទៅកាន់សិស្សផ្សេងទៀត និងគ្រូរបស់ពួកគេ។ ការតាំងពិព័រណ៌ ត្រូវតែរៀបចំទៅតាមប្រធានបទផ្សេងៗគ្នា។ ឧទាហរណ៍ ការបង្ហាញដំបូងអាចជារឿងរូបភាព និងរបាយការណ៍ពីធ្វើដំណើរទស្សនកិច្ចសិក្សាណាមួយ។ របាយការណ៍ស្តីពីការធ្វើដំណើរទស្សនកិច្ចសិក្សា គួរធ្វើឡើងនៅលើក្រដាសផ្ទាំងរូបភាព។ រូបភាពដែលល្អបំផុត ត្រូវបានជ្រើសរើស ហើយសិស្សគួរតែសរសេរការពិពណ៌នាខ្លីៗ ទៅនឹងដំណើរកម្សាន្តរបស់ពួកគេនោះ (កន្លែងដែលពួកគេបានទៅ អ្វីដែលពួកគេបានរៀន ... )។

### ៤.២.៦. ការប្រជុំឆ្លុះបញ្ចាំងសកម្មភាពប្រចាំឆ្នាំ

ការប្រជុំនេះ មានទម្រង់ជាការធ្វើទស្សនកិច្ចសិក្សា ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលបានកើតឡើងក្នុងក្លឹបអំឡុងពេលមួយឆ្នាំ។ សិស្សចំណាយពេលពិភាក្សាគ្នា ពីសកម្មភាពដែលពួកគេពេញចិត្តនៅក្នុងឆ្នាំសិក្សា។ ក្រុមអ្នកដឹកនាំក្លឹប អាចប្រើពេលនេះដើម្បីវាយតម្លៃទៅលើការអនុវត្តក្លឹប ហើយកត់សម្គាល់ចំណុចគួរកែលម្អសម្រាប់ឆ្នាំបន្ទាប់។

## ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស

### សេចក្តីផ្តើម

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លឹប គួរតែផ្អែកលើការសម្រេចចិត្តដែលត្រូវបានផ្តល់ព័ត៌មានជាមុន។ ក្នុងការវាយតម្លៃចំណាប់អារម្មណ៍សិស្សឱ្យចូលរួមក្នុងក្លឹប គ្រូសម្របសម្រួលជាដំបូងត្រូវផ្តល់ព័ត៌មានណែនាំ ថាតើក្លឹបនេះគឺជាអ្វី? វាអាចត្រូវបានធ្វើឡើងតាមរយៈការពន្យល់ដោយមាត់ទទេ ទៅកាន់សិស្សក្នុងថ្នាក់ ឬការពន្យល់ដោយសរសេរបិទនៅតាមទីធ្លាសាលារៀន ឬទាំងពីររបៀបក៏បាន។ ចំណុចមួយចំនួនដែលត្រូវបានរៀបរាប់នៅក្នុងការណែនាំគួររួមបញ្ចូលនូវចំណុចខាងក្រោម៖

- **វត្ថុបំណង៖** ផ្តល់បរិយាកាសដល់សិស្សដើម្បីស្វែងយល់បច្ចេកវិទ្យាថ្មីៗ តាមរយៈការប្រើប្រាស់ម៉ាស៊ីនថតរូបឌីជីថល រៀនមូលដ្ឋានគ្រឹះនៃការថតរូប ត្រិះរិះពិចារណាពីការថតរូប អភិវឌ្ឍជំនាញថតរូប និងគំនិតច្នៃប្រតិដ្ឋដទៃទៀត។
- **សកម្មភាព៖** បណ្តុះបណ្តាលបច្ចេកទេសជាមូលដ្ឋាន វិភាគរូបភាព ការបង្កើតប្លង់ថតផ្សេងៗគ្នាបង្កើតខ្សែរឿងរូបថត(ខ្សែរឿងរូបភាព) ឬការបង្ហាញពីរូបថត ការរៀបចំពិព័រណ៍បណ្ណាល័យ និងដំណើរទស្សនកិច្ចសិក្សានានា។
- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សធ្វើសកម្មភាព ពីព្រោះពួកគេចង់ធ្វើ មិនមែនពួកគេត្រូវបានបង្ខំឱ្យធ្វើនោះទេ។
- **ការចូលរួម៖** សមាជិកនៃក្លឹប គឺតាមរយៈការស្ម័គ្រចិត្ត។
- **ការប្រជុំ៖** មានការប្រជុំជាទៀងទាត់ (ប្រហែល២សប្តាហ៍ ប្រជុំម្តង) ដើម្បីពិភាក្សា សកម្មភាពដែលបានគ្រោងទុក។ ការប្រជុំ នឹងត្រូវធ្វើឡើងក្រៅម៉ោងសិក្សា ឬនៅពេលដែលសាលាឈប់សម្រាក។

**សំណួរបញ្ជាក់នូវចំណាប់អារម្មណ៍របស់អ្នកក្នុងការចូលរួមក្លឹបថតរូបដោយគូសសញ្ញា (✓) នៅក្នុងប្រអប់ណាមួយខាងក្រោម៖**

☐ ខ្ញុំមិនចាប់អារម្មណ៍នឹងការចូលរួមក្លឹបថតរូបនេះសោះ។

☐ ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹបថតរូប ប៉ុន្តែខ្ញុំមិនច្បាស់ថាខ្ញុំមានពេលវេលាគ្រប់គ្រាន់នោះទេ

☐ ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹបថតរូបខ្លាំងណាស់ ហើយខ្ញុំច្បាស់ថាខ្ញុំនឹងមានពេលវេលាគ្រប់គ្រាន់សម្រាប់ការចូលរួម។

# ឧបសម្ព័ន្ធទី២៖ ការបែងចែកភារកិច្ច

## ១. ប្រធាន៖

- រៀបចំការប្រជុំក្លឹប
- សម្របសម្រួលរៀបចំរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ
- សម្របសម្រួលការប្រជុំ
- ធានាថាកន្លែងប្រជុំអាចប្រើប្រាស់បាន ដោយធ្វើការសម្របសម្រួលជាមួយនឹងនាយកសាលា
- ទំនាក់ទំនងជាមួយនឹងសមាជិកក្លឹប និងគណៈកម្មការមធ្យមសិក្សាសាលាធនធាន
- តាមដានការអនុវត្តផែនការសកម្មភាពក្រុម
- រាយការណ៍អំពីបញ្ហាដល់គ្រូសម្របសម្រួលក្លឹប ប្រសិនបើមាន

## ២. អនុប្រធាន

- បំពេញតួនាទីជាប្រធាន នៅពេលប្រធានអវត្តមាន
- ជួយសម្របសម្រួលការប្រជុំ
- សរសេរកំណត់ហេតុប្រជុំ

## ៣. ហេរញ្ញិក

- ទទួលខុសត្រូវចំពោះថវិកាដែលទទួលបានពីគ្រូដឹកនាំ ទទួលខុសត្រូវក្លឹបសម្រាប់សកម្មភាពផ្សេងៗ រួមមាន ការស្នើទិញសម្ភារៈសម្រាប់ការតាំងពិព័រណ៍ ការចុះតាមមូលដ្ឋាន។ល។
- ថែរក្សាទុកកំណត់ត្រាថវិកាទាំងអស់ពេលដែលបានទទួលពីគ្រូដឹកនាំក្លឹប។
- រៀបចំសំណើរ ឬចំណាយតាមការណែនាំរបស់គ្រូដឹកនាំក្លឹប។

## ៤. ប្រធានក្រុម

- ផ្តល់ភាពជាអ្នកដឹកនាំដល់ក្រុម
- ធ្វើរបាយការណ៍ក្នុងនាមតំណាងក្រុមជូនទៅប្រធានក្លឹប ឬគ្រូដឹកនាំក្លឹប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធាន ឬគ្រូដឹកនាំក្លឹបដល់សមាជិកក្រុម

## *គ្រូសម្របសម្រួលក្លឹប៖

- ផ្តល់ការណែនាំទូទៅពីគោលការណ៍ក្លឹបក្នុងការរៀបចំផែនការប្រជុំ ដឹកនាំការប្រជុំលើកទី១ ជ្រើសរើសប្រធានក្លឹប ប្រធានក្រុម អាចធ្វើការងារជាច្រើនបានដោយខ្លួនឯង។
- ផ្តល់ការគាំទ្របច្ចេកទេសក្លឹប(សម្របសម្រួលសម្ភាររូបវន្ត និងសកម្មភាពផ្សេងៗ)
- ជាអ្នកតំណាងក្លឹបចំពោះមុខគណៈកម្មការសាលាមធ្យមសិក្សាធនធានក្នុងពេលដំណើរការថវិកា
- សម្របសម្រួលសកម្មភាពរួមមាន ការធ្វើផែនការ និងសមិទ្ធផលដែលបានបង្កើតឡើង
- សម្របសម្រួលរវាងក្លឹប និងរដ្ឋបាលសាលាក្នុងការប្រើប្រាស់បណ្ណាល័យ ឬកន្លែងប្រជុំផ្សេងៗ។
- ត្រួតពិនិត្យធនធានថវិកាក្លឹប

## ឧបសម្ព័ន្ធទី៣៖ កំណត់ផែនការ

ត្រីមាសទី១

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ៦ | | | | | | | | | | | | |
| ៧ | | | | | | | | | | | | |
| ៨ | | | | | | | | | | | | |
| ៩ | | | | | | | | | | | | |
| ១០ | | | | | | | | | | | | |
| ១១ | | | | | | | | | | | | |
| ១២ | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | |

ត្រីមាសទី២

| សកម្មភាព | កុម្ភៈ | | | | មីនា | | | | មេសា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ៦ | | | | | | | | | | | | |
| ៧ | | | | | | | | | | | | |
| ៨ | | | | | | | | | | | | |
| ៩ | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | | | | | | | | | | | | |
| ១១ | | | | | | | | | | | | |
| ១២ | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | |

## ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន

| ការចំណាយ | រូបមន្ត (បរិមាណ x តម្លៃរាយ / ដុំ) | ចំនួនទឹកប្រាក់ |
|---|---|---|
| 1. ផ្ទាំងរូបភាព | ១ គីឡូក្រាម x ២ ដុល្លារ / គីឡូក្រាម | ២,០០ ដុល្លារ |
| 2. ហ្វីត | ២ ប្រអប់ x $ 2.50 / ប្រអប់ | ៥,០០ ដុល្លារ |
| 3. ក្រដាសពណ៌ A4 | ២ ដុំ x ៤ ដុល្លារ / ដុំ | ៨,០០ ដុល្លារ |
| 4. <u>ការធ្វើដំណើរទស្សនកិច្ចសិក្សា</u><br>អាហារថ្ងៃត្រង់:<br>រថយន្តឈ្នួល៖ | <br>១៥ នាក់ x ១ ដុល្លារ / នាក់<br>២៥ ដុល្លារ / ថ្ងៃ x ១ ថ្ងៃ | <br>១៥,០០ ដុល្លារ<br>២៥,០០ ដុល្លារ |
| ៥.ម៉ាស៊ីនថតរូបឌីជីថល | ? | ? |
| ៦. សម្ភារទូទៅ | | ៤៨,០០ ដុល្លារ |
| **សរុប** | | **ដុល្លារ 123.00** |